ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**(MINISTRY OF AGRICULTURE, FORESTRY AND FISHERIES)**

# ផែនការយុទ្ធសាស្ត្រថវិកា

# ២០២០-២០២២

## (BUDGET STRATEGIC PLAN 2020-2022)

រៀបចំដោយ : ក្រុមការងាររៀបចំផែនការថវិកា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

(BUDGET PLANNING PREPARATION WORKING GROUP)

រាជធានីភ្នំពេញ ខែឧសភា ឆ្នាំ២០១៩

# មាតិកា


I-សេចក្តីផ្តើម ........ 1

១. តួនាទី និងបេសកកម្មចម្បងៗ ........ 2

២. លទ្ធផលសម្រេចបានឆ្នាំ២០១៨ ........ 3

ក. លទ្ធផលសម្រេចបានតាមអនុវិស័យកសិកម្ម ........ 4

ក.១ ការបង្កើនផលិតភាព និងពិពិធកម្មដំណាំកសិកម្ម ........ 4

ក.២ ការសម្រេចបានក្នុងការជំរុញផលិតកម្មសត្វនិងសុខភាពសត្វ ........ 6

ក.៣ ការសម្រេចបានក្នុងការកែទម្រង់ផ្នែកជលផល ........ 8

ក.៤ ការសម្រេចបានក្នុងការកែទម្រង់ផ្នែកព្រៃឈើ ........ 8

ក.៥. សមត្ថភាពស្ថាប័ន សេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ........ 9

ក.៦. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........ 10

ខ. លទ្ធផលសម្រេចបានក្នុងការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........ 11

៣. បញ្ហាប្រឈម ........ 12

៤. វិធានការ ........ 12

II. គោលបំណងគោលនយោបាយ ........ 15

III. កម្មវិធី/យុទ្ធសាស្ត្រអាទិភាព ........ 16

IV. ការកំណត់សូចនាករ និងគោលដៅសូចនាករ ........ 32

V. ការកំណត់ធនធាន ........ 41

ក. ការកំណត់តម្រូវការចំណាយ ........ 41

តារាង ៤.១៖ ការកំណត់តម្រូវការចំណាយសម្រាប់កម្មវិធី២០១៩-២០២១ (រដ្ឋបាលកណ្តាល) ........ 41

តារាង៤.២៖ ការកំណត់តម្រូវការចំណាយ ២០១៩-២០២១(មន្ទីររាជធានី ខេត្ត) ........ 51

ខ. ការគ្រោងចំណូល ........ 72

តារាង ៥.១: ការគ្រោងនិងព្យាករណ៍ចំណូល (រដ្ឋបាលកណ្តាល) ........ 72

តារាង ៥.២ : ការគ្រោងនិងព្យាករណ៍ចំណូល (ថ្នាក់រាជធានី ខេត្ត) ........ 74

VI. សេចក្តីសន្និដ្ឋាន ........ 76

## I- សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញទិសដៅជាយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា២០១៣-២០២០ ដែលជាទិសដៅនៃការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងថវិកាជាជំហានៗ ពីការផ្តោតលើធាតុចូលនិងមធ្យោបាយទៅរកប្រព័ន្ធថវិកាថ្មី គឺការផ្តោតលើលទ្ធផលឬសមិទ្ធកម្មនិងវិមជ្ឈការ។ បន្ទាប់មកថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រនៃកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា២០១៨-២០២៥ គឺផ្តោតលើប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព។ ផ្អែកតាមទិសដៅនៃកម្មវិធីកែទម្រង់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាក្រសួងមួយក្នុងចំណោមក្រសួងដែលត្រូវបានដាក់ឲ្យអនុវត្តថវិកាកម្មវិធីពេញលេញ ដោយមានការវិភាជថវិកា និងការធ្វើប្រតិភូកម្មសិទ្ធិអំណាចក្នុងការអនុវត្តចំណាយថវិកាដល់បណ្តាអង្គភាពថវិកាមួយចំនួនដែលបានបង្កើតឡើងនាពេលកន្លងមក។

ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានរៀបចំស្របតាមខ្លឹមសារនៃសារាចរណែនាំលេខ០៥សរណន ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ និងបានគ្របដណ្តប់ថវិកាទាំងអង្គភាពបច្ចេកទេសថ្នាក់កណ្តាល គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តទាំង២៥។

បន្ថែមលើនេះទៀតនោះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣ ក៏ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៩នេះ ស្របតាមទិសដៅគោលនយោបាយតាមវិស័យដែលមានចែងក្នុងផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា។ គោលបំណងគោលនយោបាយរបស់ក្រសួងត្រូវបានកំណត់ច្បាស់លាស់ និងបង្កើតបាននូវរចនាសម្ព័ន្ធកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព រួមទាំងការកំណត់នូវសូចនាករសម្រាប់អនុវត្តប្រកបដោយប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយ។ ផ្អែកលើមូលដ្ឋាននេះ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ ក៏ត្រូវបានរៀបចំឲ្យមានសង្គតិភាព ជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មផងដែរ។

ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការរៀបចំផែនការថវិកា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកែសម្រួលនូវសមាសភាពក្រុមការងារចំនួន២ គឺៈ (១)ក្រុមការងាររៀបចំថវិកា និង(២)ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួង ដែលក្រុមទាំង២នេះដឹកនាំដោយឯកឧត្តមរដ្ឋលេខាធិការក្រសួង និងមានសមាសភាពចម្រុះពីអង្គភាពសំខាន់ៗ ពិសេសពីនាយកដ្ឋានផែនការនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ។

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានបង្ហាញច្បាស់លាស់ក្នុងឯកសារនៃសារាចរណែនាំរបស់រាជរដ្ឋាភិបាល។ ស្របជាមួយនេះ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ត្រូវបានកសាងឲ្យមានសង្គតិភាពជាមួយគោលនយោបាយខាងលើ ដែលអាចជាមូលដ្ឋានសម្រាប់អនុវត្តប្រកបដោយប្រសិទ្ធភាព។

រចនាសម្ព័ន្ធនៃឯកសារផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងរៀបចំជា៦ផ្នែកសំខាន់រួមមានៈ

(ផ្នែកទី១)ៈ គឺបង្ហាញពីតួនាទីនិងបេសកកម្មរបស់ក្រសួង វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំកន្លងមក បញ្ហាប្រឈមនានា និងវិធានការគោលនយោបាយសំខាន់ៗ សម្រាប់រួមចំណែកអនុវត្តយុទ្ធសាស្ត្រថ្មីរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣។

(ផ្នែកទី២)ៈ ការកំណត់គោលបំណងគោលនយោបាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយបង្ហាញពីចក្ខុវិស័យរយៈពេលមធ្យមនិងវែង ផ្អែកលើគោលនយោបាយតាមវិស័យ ដែលនឹងចែងក្នុងយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

(ផ្នែកទី៣)៖ ការរៀបចំកម្មវិធីថ្មីទាំង៥របស់ក្រសួង ឲ្យឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយរបស់ក្រសួងដូចដែលបានរៀបរាប់ក្នុងផ្នែកទី២ខាងលើ ដែលកម្មវិធីទាំង៥នេះមានលក្ខណៈសមាហរណកម្ម និងគ្របដណ្តប់លើគម្រោង/សកម្មភាពការងារទាំងអស់ ទាំងរវាងគម្រោង/សកម្មភាពការងារ ដែលផ្តល់ហិរញ្ញប្បទានដោយថវិការដ្ឋ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍នានា ហើយផ្នែកនេះក៏នឹងបង្ហាញពីតម្រូវការធនធានសម្រាប់អនុវត្ត ដែលរួមទាំងថវិកាជាតិ និងថវិកាដៃគូអភិវឌ្ឍន៍ផងដែរ។

(ផ្នែកទី៤)៖ ការកំណត់សូចនាករ និងគោលដៅសូចនាករ ដែលជាមូលដ្ឋានសម្រាប់ការតាមដាននិងវាយតម្លៃនៃការអនុវត្តកម្មវិធីទាំង៥របស់ក្រសួង។

(ផ្នែកទី៥)៖ ការកំណត់តម្រូវការចំណាយសម្រាប់អនុវត្តរយៈពេល៣ឆ្នាំ (២០២០-២០២២) តាមកម្មវិធីនីមួយៗ និងការគ្រោងចំណូលផ្អែកលើលទ្ធផល និងបទពិសោធន៍ក្នុងការអនុវត្តនៃបណ្តាឆ្នាំកន្លងមក។

(ផ្នែកទី៦)៖ ជាផ្នែកចុងក្រោយដែលនឹងបង្ហាញពីសេចក្តីសន្និដ្ឋាន ទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៩-២០២១ និងការលើកទិសដៅនិងវិធានការនានា ដើម្បីសម្រេចបានតាមគោលដៅដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រថវិកានេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានពិនិត្យវាយតម្លៃអង្គភាពក្រោមឱវាទ តាមលក្ខខណ្ឌវិនិច្ឆ័យទាំង៧នៃអង្គភាពថវិកា និងបានកំណត់អង្គភាពថវិកាចំនួន៤៥ ដែលត្រូវយកទៅអនុវត្តចាប់ពីឆ្នាំ២០១៧កន្លងទៅនេះ ក្នុងនោះ អង្គភាពថ្នាក់កណ្តាលចំនួន២០អង្គភាព និងថ្នាក់រាជធានី ខេត្ត (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត) ចំនួន២៥អង្គភាព។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាពឲ្យអង្គភាពថវិកាទាំង៤៥អង្គភាពនេះ បានដំណើរការអនុវត្តការងាររបស់ខ្លួន។

## ១. តួនាទី និងបេសកកម្មចម្បងៗ

**ចក្ខុវិស័យរយៈពេលវែងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺដើម្បី៖** "កសិកម្មកម្ពុជាជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុនិងនិរន្តរភាព ដែលនាំដល់ការកើនឡើងប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា"

**បេសកកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺដើម្បី៖** ផ្តល់សេវាគាំទ្រមាន គុណភាពខ្ពស់ មានលក្ខណៈវិទ្យាសាស្ត្របច្ចេកទេស បទដ្ឋានគតិយុត្ត និងគោលនយោបាយច្បាស់លាស់ សម្រាប់បម្រើឲ្យការអភិវឌ្ឍវិស័យកសិកម្មកម្ពុជាប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

ដោយឡែកអនុក្រឹត្យលេខ១៧ អនក្រ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ បានកំណត់យ៉ាងច្បាស់ពីមុខងារ និង ភារកិច្ច របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដូចតទៅ ៖

(ក)-រៀបចំនិងដាក់ឱ្យដំណើរការនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ក្នុងគោលបំណងកែលម្អកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ សម្របសម្រួលតាមដាន និងវាយតម្លៃលើការអនុវត្តនយោបាយ និងសកម្មភាពអភិវឌ្ឍន៍កសិកម្ម ។

(ខ)-សិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយអំពីវិទ្យាសាស្ត្របច្ចេកទេស និងសេដ្ឋកិច្ចក្នុងវិស័យកសិកម្មគ្រប់ផ្នែកចាំបាច់ដល់កសិករ ដើម្បីកែលម្អផលិតកម្មនិងផលិតភាពកសិកម្ម។

(គ)-ណែនាំការងារអភិវឌ្ឍន៍ដីនិងការកែលម្អគុណភាពដី ការប្រើប្រាស់ដីកសិកម្ម ពូជរុក្ខជាតិ ពូជសត្វ ជីគីមី និងថ្នាំកសិកម្មឱ្យបានសមស្របទៅតាមលក្ខណៈភូមិសាស្ត្រ អាកាសធាតុរបស់តំបន់ ដើម្បីធានាបានទិន្នផលខ្ពស់ និងរក្សាគុណភាពបរិស្ថានធម្មជាតិ។

(ឃ)-តាមដានការវិវត្តន៍នៃធនធានធម្មជាតិរបស់វិស័យកសិកម្ម និងសម្រួលដល់ការធ្វើអាជីវកម្មធនធានធម្មជាតិទាំងនោះ ដើម្បីបំពេញតម្រូវការរបស់ប្រទេសជាតិ និងគោរពលំនឹងអេកូឡូស៊ី កំណត់បទប្បញ្ញត្តិក្នុងការគ្រប់គ្រងថែរក្សាការពារធនធានធម្មជាតិរបស់វិស័យកសិកម្ម និងតាមដានការអនុវត្ត។

(ង)-វាយតម្លៃនិងបណ្តុះបណ្តាលធនធានមនុស្ស សម្រាប់ចូលរួមក្នុងការអភិវឌ្ឍកសិកម្ម ដោយលើកកម្ពស់កម្រិតយល់ដឹងបច្ចេកទេស និងបង្កលក្ខណៈប្រើប្រាស់ធនធាននេះឱ្យមានប្រសិទ្ធភាព។

(ច)-ប្រមូលចំណូលរដ្ឋ ដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការប្រមូលចំណូល។

## ២. លទ្ធផលសម្រេចបានឆ្នាំ២០១៨

ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជានឹងឈានដល់ដំណាក់កាលប្រែប្រួលថ្មីមួយទៀត ដែលជាអន្តរកាលឆ្ពោះទៅរកការ សម្រេចឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់សម្រាប់រយៈពេលមធ្យមខាងមុខ។ ដើម្បីសម្រេចបាននូវកិច្ចការនេះ ទាមទារឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យកចិត្តទុកដាក់ពង្រឹងបន្ថែមទៀត នូវគោលនយោបាយ យន្តការនិងរចនាសម្ព័ន្ធអនុវត្ត សំណុំវិធានច្បាប់ ធនធានមនុស្ស មធ្យោបាយ និងធនធានហិរញ្ញវត្ថុ ដើម្បីដំណើរការអភិវឌ្ឍន៍កសិកម្មតាមបែបទំនើបភាវូបនីយកម្ម និងរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះតម្រូវការ ការរំពឹងទុករបស់រាជរដ្ឋាភិបាល អ្នកទទួលផលពីវិស័យកសិកម្ម និងប្រជាកសិករនៅជនបទ ដោយទាញយកផលប្រយោជន៍ជាអតិបរិមាពីការរីកចម្រើនផ្នែកបច្ចេកវិទ្យា និងឌីជីថលូបនីយកម្ម ជាពិសេសពីបរិការណ៍នៃបដិវត្តន៍ឧស្សាហកម្មទី៤។

វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ២៣,៥% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៨។ តម្លៃបន្ថែមសរុបនៃវិស័យកសិកម្មបានកើនពី ១៩ ៤៧០ពាន់លានរៀល នៅឆ្នាំ២០១៤ ដល់ ២១ ៩១៣ពាន់លានរៀល នៅឆ្នាំ២០១៨ (ប្រភពទិន្នន័យពីក្រសួងផែនការ ២០១៨)។

នៅឆ្នាំ២០១៨កន្លងមកនេះ អត្រានៃការចូលរួមចំណែករបស់អនុវិស័យ ក្នុងផលិតផលក្នុងស្រុកសរុបនៃវិស័យកសិកម្មរួមមាន៖ ផ្នែកដំណាំ៥៣,១% ផ្នែកផលិតកម្មសត្វ១១,១% ផ្នែកជលផល២៤% និងផ្នែកព្រៃឈើ៦,៧%។ ជាការកត់សម្គាល់ ផលិតកម្មដំណាំនិងជលផល គឺជាកម្លាំងចលករនាំមុខក្នុងផលិតកម្មកសិកម្ម។ តាមរយៈលទ្ធផលកំណើន ជាវិជ្ជមាននេះ គឺបានបញ្ជាក់ឲ្យឃើញថា វិសយ័កសិកម្មបានអភិវឌ្ឍចំគោលដៅដែលបានគ្រោងទុក បើទោះបីជាវិស័យនេះទទួលរងនូវផលប៉ះពាល់ដោយសារតម្លៃកសិផលទាបនៅក្នុងទីផ្សារអន្តរជាតិ ការបាត់បង់កម្លាំងពលកម្មនៅជនបទ និងភាពងាយរងគ្រោះដោយកត្តាបម្រែបម្រួលអាកាសធាតុ និងកត្តាធម្មជាតិផ្សេងៗក៏ដោយ។ ផលិតកម្មសត្វគឺជាមុខព្រួញសំខាន់មួយទៀត ក្នុងការផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងការនាំចេញ ដែលផ្នែកនេះត្រូវជំរុញអភិវឌ្ឍឲ្យបានខ្លាំងក្លាផងដែរ។

ផលិតកម្មសត្វក៏មានការរីចចម្រើនគួរជាទីពេញចិត្ត ពិសេសការកើនឡើងនៃកសិដ្ឋានចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មមានប្រមាណ១៩%ធៀបនឹងផលិតកម្មសត្វសរុបក្នុងឆ្នាំ២០១៧ និងអនុវិស័យនេះក៏បានចូលរួមលើកកម្ពស់សន្តិសុខស្បៀង ទ្រទ្រង់ជីវភាពរបស់កសិករក្រីក្រ និងជាប្រភពក្នុងការផ្តល់ប្រាក់ចំណូល អាហារូបត្ថម្ភ ប្រភពថាមពលកកើតឡើងវិញ និងជីសរីរាង្គ។ ចំពោះការកែទម្រង់លើវិស័យព្រៃឈើនិងជលផលក៏មានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ផងដែរ។ ទន្ទឹមនឹងនោះ ការលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចការពារ និងអភិរក្សបរិស្ថាន ធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ជីវចម្រុះ ព្រៃឈើ និងជម្រកសត្វ ព្រមទាំងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុក៏បានទទួលលទ្ធផលជោគជ័យផងដែរ។

សារៈសំខាន់របស់វិស័យកសិកម្ម ត្រូវបានស្តែងឲ្យឃើញតាមរយៈ ក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាច្រើន ដែលបានផ្តោតជាសំខាន់លើការជំរុញ និងលើកស្ទួយវិស័យកសិកម្ម ជាមួយនឹងរបត់ថ្មី ដើម្បីឈានឆ្ពោះទៅរកការពន្លឿនកំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័ស។ បន្ថែមលើសពីនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដែល

មានគោលដៅសំខាន់ពាក់ព័ន្ធនឹងវិស័យកសិកម្ម គឺត្រូវជំរុញការនាំចេញទំនិញកែច្នៃកសិកម្មឲ្យបាន១២% នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០២៥។ ក្នុងន័យនេះ ការធ្វើឲ្យប្រាកដនូវរាល់គោលដៅ ក្នុងការងារអភិវឌ្ឍន៍វិស័យកសិកម្មកម្ពុជាត្រូវចាប់ច្បាមនូវកាលានុវត្តភាពនេះឲ្យបាន ជាពិសេសត្រូវធ្វើឲ្យកម្ពុជាមានឧត្តមភាពប្រកួតប្រជែងទីផ្សារក្នុងស្រុក និងការនាំចេញកសិផល ទាំងក្នុងតំបន់និងពិភពលោក និងកាត់បន្ថយការនាំចូល។

ក្រសួងក៏បានទទួលស្គាល់ផងដែរថា ប្រព័ន្ធកសិកម្មនៅកម្ពុជាភាគច្រើនជាកសិកម្មផ្គត់ផ្គង់ក្នុងក្រុមគ្រួសារខ្លួនឯង ហើយនៅមានកង្វះខាតចំណេះដឹងអំពីកសិកម្មផ្គត់ផ្គង់ជាលក្ខណៈពាណិជ្ជកម្ម ដែលតែងតែទទួលរងនូវផលប៉ះពាល់ពីបាតុភូតធម្មជាតិជាអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ដោយសារការដាំដុះរបស់កសិករភាគច្រើននៅមានការពឹងពាក់លើទឹកភ្លៀង និងការសាងសង់ប្រព័ន្ធស្រោចស្រពពុំទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយ និងកង្វះខាតនូវទំនាក់ទំនង ជាមួយនឹងការយល់ដឹងអំពីទីផ្សារ និងការធ្វើកសិ-ពាណិជកម្ម។ ទាំងអស់នេះ ជាមូលហេតុមួយដែលធ្វើឲ្យផលិតកម្មកសិកម្មមានការប្រែប្រួលជារៀងរាល់ឆ្នាំ។

ក្នុងគោលបំណងធ្វើឲ្យសម្រេចបាននូវការធ្វើទំនើបភាវូបនីយកម្មកសិកម្ម ដែលអាចចូលរួមជួយដោះស្រាយបញ្ហាប្រឈមរបស់កសិករ និងសហគមន៍កសិកម្ម រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការប្រទាក់ក្រឡាចាំបាច់មួយចំនួនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពទៅលើការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ទាក់ទងទៅនឹងខ្សែច្រវាក់ផលិតកម្មកសិកម្ម និងការបង្កើនឧត្តមភាពប្រកួតប្រជែងនៅលើទីផ្សារដូចជា ឃ្លាំងស្តុកកសិផល ផ្លូវថ្នល់ ការរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹក ការចែកចាយថាមពលអគ្គិសនី ការផ្តល់សេវាបច្ចេកទេស និងកែលម្អធាតុចូលកសិកម្ម ការកែទម្រង់ការគ្រប់គ្រងដីធ្លី និងហិរញ្ញវត្ថុក្នុងការវិនិយោគ ការរៀបចំយន្តការនានាឆ្ពោះទៅដណ្តើមទីផ្សារ ការរៀបចំនិងអភិវឌ្ឍសហគមន៍កសិកម្ម និងពង្រឹងយន្តការសម្របសម្រួលស្ថាប័ន។

## ក. លទ្ធផលសម្រេចបានតាមអនុវិស័យកសិកម្ម

### ក.១ ការបង្កើនផលិតភាព និងពិពិធកម្មដំណាំកសិកម្ម

**- ផលិតកម្មដំណាំស្រូវ**

ផ្ទៃដីភ្ជួររាស់ដាំដុះដំណាំស្រូវឆ្នាំ២០១៨-២០១៩ នៅទូទាំងប្រទេសសម្រេចបានចំនួន៣,៦៤លានហ.ត ក្នុងនោះផ្ទៃដីភ្ជួររាស់ដោយគ្រឿងយន្តកសិកម្មចំនួន៣,៥២លានហ.ត ឬស្មើនឹង៩៦,៨៦%។ ផ្ទៃដីដាំដុះដំណាំស្រូវសម្រេចបានលើផ្ទៃដី៣លានហិកតានៅឆ្នាំ២០១៤ និងបានកើនដល់ ៣,៣៥លានហិកតានៅឆ្នាំ២០១៨។ ទិន្នផលស្រូវគិតជាមធ្យមទាំងប្រាំងនិងវស្សាបានកើនពី ៣,០៧៩តោន/ហ.ត ពីឆ្នាំ២០១៤ ដល់ ៣,៣៥៣តោន/ហ.ត នៅឆ្នាំ២០១៨។ បរិមាណផលស្រូវបានកើនឡើងពី ៩,៣២លានតោននៅឆ្នាំ២០១៤ ដល់ប្រមាណ ១០,៨៩លានតោននៅឆ្នាំ២០១៨។ អតិរេកស្រូវបានកើនពី ៤,៧លានតោននៅឆ្នាំ២០១៤ ដល់ប្រមាណ ៥,៨លានតោននៅឆ្នាំ២០១៨នេះ។

គួរកត់សម្គាល់ថា បច្ចុប្បន្ននេះផលិតកម្មដំណាំស្រូវមានការវិវឌ្ឍឈានឡើងជាលំដាប់ គឺដោយសារមានការគាំទ្រយ៉ាងខ្លាំងក្លា ពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា អង្គការជាតិនិងអន្តរជាតិ អាជ្ញាធរថ្នាក់ក្រោមជាតិ វិស័យឯកជន និងការចូលរួមយ៉ាងសកម្មពីប្រជាកសិករ។ ការសម្រេចបានក្នុងការបង្កើនផលិតភាពដំណាំស្រូវបណ្តាលមកពីកត្តាសំខាន់ៗ មួយចំនួន ដូចជា៖

១) ការផ្លាស់ប្តូរពូជស្រូវមានទិន្នផលខ្ពស់ ដែលជាលទ្ធផលទទួលបានពីការពិសោធន៍ស្រាវជ្រាវ

២) ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ជាពិសេសការពង្រីកឲ្យកាន់តែមានប្រសិទ្ធភាពលើការធ្វើស្រែបង្ហាញតាមប្រព័ន្ធវប្បកម្មដំណាំស្រូវ

៣) ការអនុវត្តបច្ចេកទេសគ្រប់គ្រងដី ទឹក ដើម្បីបង្កើនជីជាតិ និងទិន្នផលដំណាំ

៤) ការបង្កើនការស្រាវជ្រាវនិងអភិវឌ្ឍពូជស្រូវ ដែលស្របនឹងលក្ខណៈដី អាកាសធាតុ

៥) ការកំណត់ប្រភេទពូជស្រូវសំខាន់ៗស្របតាមតម្រូវការទីផ្សារ ដូចជា ពូជស្រូវផ្ការំដួល។

ជាការកត់សម្គាល់បន្ថែមទៀត យន្តូបនីយកម្មកសិកម្មពិតជាបាននិងកំពុងដើរតួសំខាន់ ព្រមទាំងបំពេញនូវកម្លាំងពលកម្មដែលកំពុងខ្វះខាតក្នុងវិស័យកសិកម្មនាពេលកន្លងមក។

- **ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម**

ផលិតកម្មដំណាំសាកវប្បកម្ម និងឧស្សាហកម្ម ត្រូវបានកត់សម្គាល់ឃើញថា ផ្ទៃដីដាំដុះបានកើនពី ៩៥៣.៥៩៧ ហ.ត នៅឆ្នាំ២០១៤ ដល់ប្រមាណ ១,០៩១លានហ.ត នៅឆ្នាំ២០១៨ (កំណើនជាមធ្យមក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះមាន ប្រមាណ៣%)។ ចំពោះបរិមាណផលនៃដំណាំរួមផ្សំ និងឧស្សាហកម្មរយៈពេលខ្លីបានកើនពី ១៤,៧លានតោន នាឆ្នាំ២០១៤ ដល់ប្រមាណ ១៦,៦លានតោននាឆ្នាំ២០១៨ (កំណើនជាមធ្យមក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះមាន ប្រមាណ ១០,៥%)។

- **ការនាំចេញផលិតផលកសិកម្ម (ការធ្វើពាណិជ្ជូបនីយកម្ម)**

ការនាំចេញផលិតផលកសិកម្មមាននិន្នាការកើនឡើងជាលំដាប់ ហើយមានសន្ទុះខ្លាំងក្លានៅក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។ ជាក់ស្តែង នៅឆ្នាំ២០១៤ ការនាំចេញផលិតផលកសិកម្មសម្រេចបានចំនួន ៣,៤៤លានតោន នៅឆ្នាំ២០១៥ សម្រេចបានចំនួន៤,១៥លានតោន ឆ្នាំ២០១៦ សម្រេចបានចំនួន៤,៧លានតោន និងឆ្នាំ២០១៨ សម្រេចបានចំនួន៤,២៣លានតោន។ ជារួមកំណើននៃការនាំចេញក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះមានប្រមាណជា ២២,៨% ប្រៀបធៀបពីឆ្នាំ២០១៤ និងឆ្នាំ២០១៨។

ការនាំចេញអង្ករក៏មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។ ជាក់ស្តែងការនាំចេញអង្ករនៅឆ្នាំ២០១៤សម្រេចបានត្រឹមតែជាង ៣៨៧ពាន់តោននៅឆ្នាំ២០១៧ និងកើនដល់ជាង ៦២៦ពាន់តោន នៅឆ្នាំ២០១៨។ ដោយឡែក ការនាំចេញអង្ករនៅក្នុងឆ្នាំ២០១៨ មានប្រភេទអង្ករក្រអូប ៧៨,៨២% អង្ករសគ្រាប់វែង ១៦,៩៣% និងអង្ករចំហុយគ្រាប់វែង ៤,២៥% ទៅកាន់ទិសដៅ ៦១ប្រទេស និងមានក្រុមហ៊ុននាំចេញចំនួន៨៧ ក្រុមហ៊ុន។

- **ការផ្សព្វផ្សាយនិងអភិវឌ្ឍន៍សហគមន៍កសិកម្ម**

ក្នុងឆ្នាំ២០១៨ មន្ត្រីបច្ចេកទេសកសិកម្មខេត្ត ស្រុក ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ ព្រមទាំងប្រជាកសិករចំនួនជាង ២១ ៦២៧នាក់ ក្នុងនោះស្ត្រីមានចំនួន ៦ ៦៤៩នាក់ ឬស្មើនឹង៣១%ទទួលបានចំណេះដឹងទាក់ទងនឹងបច្ចេកទេសរៀបចំដីបច្ចេកទេសដាំដុះដំណាំស្រូវ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម កិច្ចការពារដំណាំ ការអនុវត្តកសិកម្មល្អ ការអនុវត្តកសិកម្មសរីរាង្គ បច្ចេកវិទ្យាក្រោយប្រមូលផលដំណាំការវាយតម្លៃ និងចាត់ចំណាត់ថ្នាក់ដី ការប្រើប្រាស់ថែទាំ និងជួសជុលគ្រឿងយន្តឧបករណ៍និងសម្ភារកសិកម្ម សមត្ថភាពក្នុងការវិភាគ ជី ដី ទឹក សំណល់ ថ្នាំកសិកម្ម ជាលិកាវប្បកម្ម និងគុណភាពគ្រាប់ពូជដំណាំ និងការផែនការអាជីវកម្ម រួមទាំងការគ្រប់គ្រងសហគមន៍កសិកម្ម។ ក្រៅពីនេះ ឯកសារបច្ចេកទេសកសិកម្មចំនួន ៥៣ ៧៤០ច្បាប់ ត្រូវបានបោះពុម្ពនិងចែកចាយ ព្រមទាំងអត្ថបទកសិកម្មចំនួន៦៥ប្រធានបទ ត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានសារធារណៈ ដូចជាទូរទស្សន៍និង វិទ្យុ ជាដើម។ ទន្ទឹមនឹងនេះ ក្រសួងបានដំណើរការមជ្ឈមណ្ឌលបណ្ណាល័យព័ត៌មានកសិកម្មនិងគេហទំព័រផ្សព្វផ្សាយកសិកម្ម ដែលមានឯកសារផ្សព្វផ្សាយចំនួន ៣៦៧ឯកសារ និងមានអ្នកចូលមើលឯកសារផ្សព្វផ្សាយចំនួន ៣៨ ២០១នាក់ ក្នុងឆ្នាំ២០១៨។

គិតត្រឹមឆ្នាំ២០១៨នេះ នៅទូទាំងប្រទេសមានសហគមន៍កសិកម្មសរុបចំនួន ១ ១១៦សហគមន៍ ដែលមានម្ចាស់ភាគហ៊ុនសរុបចំនួន ១៣០ ០៥៩នាក់ ក្នុងនោះមានសមាជិកនារីចំនួន ៨០ ៤៣៩នាក់ ស្មើនឹងប្រមាណ៦២% នៃសមាជិកសរុប ប្រាក់ភាគហ៊ុនសរុបចំនួនជាង ៣៧ ២៩៧លានរៀល (ជាង៩,៣លានដុល្លារអាមេរិក) និងមានដើមទុនសរុបចំនួនជាង ៦៩ ០៧៧លានរៀល (ជាង១៧,២លានដុល្លារអាមេរិក)។ ក្រៅពីសហគមន៍កសិកម្ម ក្រសួង បានជំរុញ និងចុះបញ្ជីសហភាពសហគមន៍កសិកម្មទូទាំងប្រទេសសរុបបានចំនួន៨ ដែលមានសមាជិកជាសហគមន៍ កសិកម្មចំនួន៩៧ និង ដើមទុនសរុបចំនួនជាង ៤១៣លានរៀល។

- **ការងារស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្ម**

**ការងារអភិរក្សពូជដំណាំ៖** បានប្រមូលពូជដំណាំថ្មីៗទៀតចំនួន ២៥០សំណាក មករក្សាទុក ព្រមទាំងបានដាំវាយតម្លៃ និងកំណត់លក្ខណៈពូជម្ទេសចំនួន៩៥សំណាក ត្រសក់ស្រូវចំនួន ៦១សំណាក និងល្ពៅចំនួន ១៧សំណាក។ គិតជារួមត្រឹមដំណាច់ឆ្នាំ២០១៨នេះ ពូជដំណាំចំនួន ៣៨ប្រភេទ សរុបទាំងអស់មានចំនួន ៨ ៨១២បញ្ជិក/សំណាក បានអភិរក្សនៅក្នុងធនាគារពន្ធុនៅវិទ្យាស្ថានកាឌីសម្រាប់ប្រើប្រាស់កិច្ចអភិវឌ្ឍន៍ពូជដំណាំក្នុងរយៈពេលយូរអង្វែង។

**ការបញ្ចេញពូជដំណាំចំនួន៨ពូជ៖** បានបញ្ចេញពូជស្រូវចំនួន៧ពូជ ( ខា១៤ ខា១៥ ខា១៦ ផ្ការំដួលប្រាំងដំណើបស្បៃមង្គល ស្ទាច់០២ និងផ្កាមាលតី ) និងពូជពោតដំណើបចំនួន១ពូជ( ស៊ីអឹម១ ) សម្រាប់កសិករប្រើប្រាស់។

**ការងារបច្ចេកទេស៖** បានធ្វើទិវាស្រែ និងបណ្តុះបណ្តាលកសិករសរុបចំនួន ១៦៨លើក ដែលមានកសិករចូលរួមសរុបចំនួន ៨ ៥៨០នាក់ ព្រមទាំងបានចែកគ្រាប់ពូជស្រូវជូនដល់កសិករចំនួន១ ២៣៥គ្រួសារ ដោយក្នុងមួយគ្រួសារបានចំនួន ៥គីឡូក្រាម ហើយដែលកសិករទាំងនោះផលិតជាគ្រាប់ពូជបានប្រមាណ ២៥៥តោន ទុកសម្រាប់ប្រើប្រាស់នាបណ្តាឆ្នាំក្រោយៗទៀត។ ទន្ទឹមនឹងនេះ បានបែងចែកឯកសារ និងសៀវភៅបច្ចេកទេសគ្រប់ប្រភេទចំនួន ១២៧ ៥៥០ច្បាប់ និងសរសេរបោះពុម្ពអត្ថបទវិទ្យាសាស្ត្រចំនួន ៣៣អត្ថបទ។

- **ការអភិវឌ្ឍដំណាំកៅស៊ូ**

ផ្ទៃដីកៅស៊ូកម្ពុជាសរុបបានកើនពី ៣៥៧,៨៣ពាន់ហិកតានៅឆ្នាំ២០១៤ ដល់ ៤៣៦,៦៨ពាន់ហិកតានៅឆ្នាំ២០១៨ (កើនប្រមាណ២២%) ដែលក្នុងនោះផ្ទៃដីកៅស៊ូកសិ-ឧស្សាហកម្ម (ផ្ទៃដីរបស់អតីតចម្ការកៅស៊ូរដ្ឋ ផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវ កៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) មានចំនួន ៦៤,២២% និងកៅស៊ូគ្រួសារមានចំនួន ៣៥,៧៨%។ ផ្ទៃដីកៅស៊ូគ្រួសារបានកើនឡើងពី១៤០,៣៨ពាន់ហិកតា នៅឆ្នាំ២០១៤ ដល់១៦១,១ពាន់ហ.តនៅឆ្នាំ ២០១៨ (គឺកើនប្រមាណជា១៤,៧% ពីចន្លោះឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨)។ រីឯផ្ទៃដីកៅស៊ូកសិ-ឧស្សាហកម្មក៏មានការរីកចម្រើនគួរឲ្យកត់សម្គាល់ផងដែរ ពោលគឺបានកើនពី២១៧,៤៦ពាន់ហ.ត នៅឆ្នាំ២០១៤ ដល់២៧៥,៥៧ ពាន់ហ.ត នៅឆ្នាំ២០១៨ (គឺកើនប្រមាណ២៧% ពីចន្លោះឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨)។

ទោះបីជាថ្លៃកៅស៊ូបន្តនៅទាបនិងមានកត្តាអវិជ្ជមានមួយចំនួន ដែលបានជួបប្រទះកន្លងមកក៏ពិតមែន តែជារួមសមិទ្ធផលបានសម្រេចទៅតាមគោលដៅដែលបានគ្រោងទុក។ ទាំងអស់នេះ គឺកើតឡើងដោយការខិតខំប្រឹងប្រែងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមហ៊ុនចម្ការកៅស៊ូកសិ-ឧស្សាហកម្ម ដៃគូអភិវឌ្ឍន៍នានា និងការចូលរួមយ៉ាងសកម្មពីកសិករកៅស៊ូគ្រួសារផងដែរ។ ទោះបីជាយ៉ាងនេះក្តី ការបង្កើនលទ្ធភាព និងសមត្ថភាពក្នុងការអភិវឌ្ឍឧស្សាហកម្មកៅស៊ូត្រូវតែបន្តយកចិត្តទុកដាក់ និងត្រូវជំរុញបន្ថែមទៀត ដើម្បីរួមចំណែកដោយជោគជ័យ ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

ផលិតផលកៅស៊ូក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ បានកើនជាងពីរដង គឺពី៩៧ពាន់តោន នៅឆ្នាំ២០១៤ ដល់ ២២០ពាន់តោននៅឆ្នាំ២០១៨។ ជាមួយគ្នានេះ ការនាំចេញផលិតផលកៅស៊ូក្នុងរយៈ ពេល៥ឆ្នាំកន្លងមកនេះ ក៏បានកើនជាងពីរដង គឺពី១០០ពាន់តោន នៅឆ្នាំ២០១៤ ដល់ ២១៧,៥៣ពាន់តោន នៅឆ្នាំ២០១៨។

## ក.២ ការជំរុញផលិតកម្មសត្វនិងសុខភាពសត្វ

ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផលិតកម្មសត្វគ្រប់ប្រភេទមានអត្រាកំណើនគួរឲ្យកត់សម្គាល់ គឺបានកើនពី ៣៧ ៩៤៨ ៨៧៨ក្បាល នៅឆ្នាំ២០១៤ ដល់ ៤៤ ៣៧៥ ៣៩៥ក្បាល នៅឆ្នាំ២០១៨ ដែលក្នុងនោះមាន គោចំនួន ២ ៩២៨ ៥៣៤ក្បាល ក្របីចំនួន ៥០០ ៩៩៥ក្បាល ជ្រូកចំនួន ២ ៧៤៧ ៨៥៥ក្បាល បក្សីចំនួន៣៨ ១៦៦ ៧៥១ក្បាល សេះចំនួន ៤ ២៩៦ក្បាល ចៀមចំនួន ៤៥៩ក្បាល ពពែចំនួន២៦ ៤៤៧ក្បាល និងដំរី ៥៨ក្បាល។

ការជំរុញផលិតកម្មសត្វ និងបង្កើនផលិតភាពសត្វ ជាគោលដៅអាទិភាពសម្រាប់ការធ្វើពាណិជ្ជកម្មសត្វ។ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្ម មានអត្រាកើនឡើងគួរឲ្យកត់សម្គាល់ គឺកើនពី

៦ ៣៣៥ ០០២ក្បាល នៅឆ្នាំ២០១៤ ឡើងដល់ ១០ ០៣៥ ៥៨៥ក្បាល នៅក្នុងឆ្នាំ២០១៨។ ដោយឡែកនៅក្នុងឆ្នាំ២០១៨នេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មមានកំណើន២៣% ក្នុងនោះផលិតកម្មជ្រូកលក្ខណៈពាណិជ្ជកម្មមានកំណើន៣០% និងផលិតកម្មបក្សីមានកំណើន២៤%។ អត្រានៃកំណើនផលិតសត្វជាលក្ខណៈពាណិជ្ជកម្មនេះបានឆ្លុះបញ្ចាំងឲ្យឃើញពីការផ្លាស់ប្តូរបែបផែនផលិតកម្មសត្វជាវិជ្ជមានមួយ ដើម្បីឈានទៅកែលម្អផលិតភាពសត្វ និងប្រសិទ្ធភាពសេដ្ឋកិច្ចកាន់តែប្រសើរឡើង។

ការចិញ្ចឹមគោមានការប្រែប្រួលថយចុះប្រមាណពី ៣លានក្បាលនាឆ្នាំ២០១៤ មកត្រឹមតែ ២,៩២លានក្បាលនាឆ្នាំ២០១៨។ រីឯក្របីក៏មានការប្រែប្រួលថយចុះប្រមាណពី ៥៤២ពាន់ក្បាលនាឆ្នាំ២០១៤ មកត្រឹមតែ ៥០១ពាន់ក្បាលនាឆ្នាំ២០១៨។ ការថយចុះចំពោះផលិតកម្មចិញ្ចឹមសត្វគោក្របីនេះ គឺជាការថយចុះគោក្របីអូសទាញ មូលហេតុបណ្តាលមកពីកសិករកាន់តែច្រើនឡើងៗ បោះបង់ការភ្ជួររាស់ដោយគោ ក្របី មកប្រើប្រាស់សេវាគ្រឿងយន្តកសិកម្ម (ជាង៩៤% នៃផ្ទៃដីដាំដុះដំណាំស្រូវ ត្រូវបានអនុវត្តដោយគ្រឿងយន្តកសិកម្ម) កង្វះកម្លាំងពលកម្មនៅជនបទ (ចំណាកស្រុក) មានការលំបាកក្នុងការស្វែងរកតំបន់មានទឹក និងចំណីគ្រប់គ្រាន់សម្រាប់ការចិញ្ចឹមសត្វគោក្របី។ ទន្ទឹមនឹងការថយចុះគោអូសទាញនេះ កសិករបានងាកមកចិញ្ចឹមគោមេនិងគោយកសាច់ ហើយជាមួយគ្នានោះក៏មានការចាប់ផ្តើមការវិនិយោគឯកជនចិញ្ចឹមគោសាច់វិញផងដែរ។

ការចិញ្ចឹមសត្វស្លាប (ពិសេសមាន់ ទា) មានការកើនឡើងយ៉ាងខ្លាំងរហូតដល់ជាង១៨% បើប្រៀបធៀបពីឆ្នាំ២០១៤ និងឆ្នាំ២០១៨។ ការចិញ្ចឹមជាលក្ខណៈគ្រួសារនិងកសិដ្ឋានក្នុងអំឡុងពេល៥ឆ្នាំ (ឆ្នាំ២០១៤-២០១៨) បានកើនពីជាង៣១,៥៨លានក្បាលនៅឆ្នាំ២០១៤ ដល់ជិត៣៨,១៦លានក្បាលនាឆ្នាំ២០១៨។ នេះបញ្ជាក់ឲ្យឃើញថាមានកំណើនការវិនិយោគក្នុងការចិញ្ចឹមសត្វស្លាប ពិសេសការចិញ្ចឹមមាន់ទា ក្នុងគោលដៅពាណិជ្ជកម្មរបស់កសិករ។

ការផលិតចំណីសត្វ មានការវិនិយោគបង្កើតរោងចក្រចំណីសត្វ សម្រាប់ផ្គត់ផ្គង់តម្រូវការ ប្រើប្រាស់ក្នុងស្រុកពីផ្នែកឯកជន។ ជាមួយគ្នានេះ ប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការដាំដុះដំណាំចំណីសត្វ ព្រមទាំងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីសត្វផ្សំស្រេចយ៉ាងផុលផុស។ ទោះជាយ៉ាងនេះក្តី ចំណីនិងថ្នាំសត្វនៅមានតម្លៃខ្ពស់នៅឡើយ ដែលទាមទារឲ្យមានការធ្វើអន្តរាគមន៍សម្រាប់បន្ទាបថ្លៃដើម។

ជាការកត់សម្គាល់ ប្រជាកសិករមានការយល់ដឹងបណ្តើរៗ នូវបច្ចេកទេសចិញ្ចឹមសត្វតាមគោលការណ៍ជីវសុវត្ថិភាព និងការយល់ដឹងអំពីវិធានការទប់ស្កាត់ជំងឺឆ្លង។ ការបង្ការការពារសុវត្ថិភាពមនុស្ស សត្វក៏ត្រូវបានអនុវត្ត និងទទួលបានលទ្ធផលល្អប្រសើរ ដោយអត្រាឈឺស្លាប់សត្វមានកម្រិតទាប។ ជាមួយនេះ ជំងឺផ្តាសាយបក្សីត្រូវបាន ទប់ស្កាត់ ការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ ត្រូវបានយកចិត្តទុកដាក់ដោយអនុវត្តចាប់ផ្តើមពីកសិដ្ឋាន កន្លែងពិឃាដដល់ទីផ្សារ ជាពិសេសការត្រួតពិនិត្យអនាម័យក្នុងការនាំចេញ នាំចូល នាំឆ្លងកាត់សត្វ និងផលិតផលមានដើមកំណើតពីសត្វ។

ការកែលម្អពូជ គឺកំពុងតែឈានឆ្ពោះទៅមុខជាបណ្តើរៗផងដែរ ព្រោះប្រជាកសិករភាគច្រើនកាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វ ជាកត្តាសំខាន់ដែលផ្តល់ទិន្នផលខ្ពស់ ការលូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ ហើយនឹងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់។ ជាមួយគ្នានោះ ការផ្សព្វផ្សាយបច្ចេកទេសក្នុងជួរកសិករត្រូវបានអនុវត្តយ៉ាងសកម្ម និងមានប្រសិទ្ធភាព ដែលជាលទ្ធផលចំនួនសត្វស្លាបមានការកើនឡើង និងធានាបាននូវការផ្គត់ផ្គង់សាច់ស៊ុតនៅក្នុងប្រទេស ហើយកសិដ្ឋានផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មកំពុងរីកចម្រើនជាបណ្តើរៗគួរឲ្យកត់ សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ។

ការអភិវឌ្ឍវិស័យចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វ ក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់ តាមរយៈការអប់រំណែនាំ ផ្សព្វផ្សាយការអនុវត្តល្អប្រសើរលើការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាម

គ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិ បាននិងកំពុងអនុវត្តយ៉ាងសកម្មផុសផុល ដែលមកទល់ឆ្នាំ២០១៨ ឡជីវឧស្ម័នសរុបចំនួន ២៧ ២៣៣ឡ ត្រូវបានសាងសង់នៅតាមខេត្តគោលដៅចំនួន១៣។

## គ.៣ ការគ្រប់គ្រងធនធានជលផល និងអភិវឌ្ឍវារីវប្បកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានរដ្ឋបាលជលផលជាសេនាធិការ បានបំពេញភារកិច្ចយ៉ាងសកម្ម ដោយសម្រេចបានលទ្ធផលគ្រប់ផ្នែកលើវិស័យជលផល ក្នុងនោះមានការរៀបចំ លិខិតបទដ្ឋានក្រោមច្បាប់ ការពង្រឹងសហគមន៍នេសាទ ការគ្រប់គ្រងកន្លែងអភិរក្សជលផល ការបង្ក្រាបបទល្មើស នេសាទ ការអភិវឌ្ឍវារីវប្បកម្ម ការសិក្សាស្រាវជ្រាវ និងការផ្សព្វផ្សាយជាដើម។ល។ ដោយឡែក ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានបច្ចេកទេសមួយចំនួនទៀតបានកំពុងពិនិត្យ ធ្វើវិសោធនកម្ម កែសម្រួល និងអនុម័ត ដើម្បីដាក់ឱ្យអនុវត្តធានាដល់ការគ្រប់គ្រងធនធានជលផល និងអនុវត្តវារីវប្បកម្មប្រកបដោយប្រសិទ្ធភាព។ ជាមួយគ្នានេះដែរ ក្រសួងបានសហការជាមួយដៃគូអភិវឌ្ឍន៍នានាក្នុងការផ្សព្វផ្សាយច្បាប់ ពង្រឹងសមត្ថភាពមន្ត្រី ពង្រឹងសហគមន៍នេសាទ ផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម និងការអភិរក្សធនធានជលផល ដែលទាក់ទងដល់ការ គ្រប់គ្រងវិស័យជលផល។

នៅក្នុងឆ្នាំ២០១៨នេះ សហគមន៍នេសាទទូទាំងប្រទេសមានចំនួនសរុប៥១៦សហគមន៍ ក្នុងនោះសហគមន៍នេសាទទឹកសាបចំនួន៤៧៥ និងសហគមន៍នេសាទសមុទ្រចំនួន៤១ ដែលមានសមាជិកសរុបចំនួន៣៣២ ១៦៨នាក់ (ស្ត្រីប្រមាណ៣៥%) ត្រូវជា១៤៧ ៥១៨គ្រួសារ។ ក្នុងចំណោមសហគមន៍ខាងលើនេះ មានសហគមន៍នេសាទចំនួន៤១១ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការងារបោះបង្គោលកំណត់ព្រំប្រទល់កន្លែងអភិរក្សជលផល៨ម៉ែត្រ បានចំនួន១៨៨បង្គោល និងកម្ពស់ ១២ម៉ែត្រចំនួន៧៩បង្គោល សាងសង់ស្នាក់ការបណ្តែតទឹកតូចចំនួន២៥ខ្នង ស្នាក់ការល្បាតបណ្តែតទឹកចំនួន ៤ខ្នង ស្នាក់ការបេតុង ០៨ខ្នង និងស្នាក់ការធំ(ស្រឡង់)ចំនួន ០៤ខ្នង ព្រមទាំងបានដាក់កម្លាំងយាមល្បាតជាប្រចាំ។ សកម្មភាពអភិរក្សជលផលផ្សេងៗទៀតរួមមាន៖ បានអភិរក្សផ្កាថ្ម ស្មៅសមុទ្រចំនួន៤ ០៥០ហ.ត នៅតាមតំបន់ឆ្នេរ ដាំព្រៃលិចទឹកនិងព្រៃកោងកាងបានចំនួន៨០ហ.ត រៀបចំអន្លង់ ត្រីមេពូជបានចំនួន៩៧កន្លែងនៅតំបន់មេគង្គលើក្នុង ខេត្តក្រចេះ និងស្ទឹងត្រែង លែងកូនត្រីនិងកូនបង្កងចំនួន៤,៥លានក្បាល ទៅក្នុងបឹងធម្មជាតិ អភិរក្សធនធានជលផល កំពុងរងគ្រោះថ្នាក់ដូចជាអណ្តើកសរសៃ អណ្តើកសមុទ្រ កន្ធាយក្បាលកង្កែប ក្រពើត្រី ផ្សោតទឹកសាប ផ្សោតទឹកប្រៃ និងសេះសមុទ្រ។ល។ ដែលធ្វើឱ្យចំនួនកើនឡើងចន្លោះ ពី០៥-១០% ទម្លាក់ប្រអប់បេតុងចំនួន១៥៥ប្រអប់សម្រាប់ជា ជម្រកសិប្បនិម្មិតនឹងរារាំងការនេសាទដោយអួនអូស ចុះបញ្ជីកសិដ្ឋានចិញ្ចឹមក្រពើចំនួន៤០០កសិដ្ឋាន និងរៀបចំ សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិរក្សធនធានជលផលឆ្នាំ២០១៩-២០២៩។ ទន្ទឹមនេះ ក្រសួងបង្ក្រាបបទល្មើស បានចំនួន២០៤ករណី (សមុទ្រ ២៣៤ករណី) ប្រៀបធៀបឆ្នាំមុនថយចុះចំនួន ៧២១ករណី ក្នុងនោះបានបំផ្លាញចោលវត្ថុតាងចំនួន ២ ៩៥០ករណី ពិន័យអន្តរការណ៍ចំនួន១៣០ករណី បញ្ជូនទៅតុលាការចំនួន១២៤ករណី ជាប់ពន្ធនាគារចំនួន៤២នាក់ ប្រាក់ពិន័យនិងលក់វត្ថុតាងចំនួន២៣០ ០៣៣ ៥០០រៀល។

ផលត្រីសរុបក្នុងឆ្នាំ២០១៨កន្លងទៅ បានចំនួន៩១០ ១៥៣តោន នេសាទទឹកសាបអនុវត្តបានចំនួន ៥៣៥ ០០៥តោន ផលនេសាទសមុទ្រអនុវត្តបាន១២១ ១០០តោន និងការអភិវឌ្ឍវារីវប្បកម្មទាំងទឹកសាប និងសមុទ្រ អនុវត្តបានប្រមាណ ២៥៤ ០៤៨តោន។ ទន្ទឹមនឹងនេះ ឧបករណ៍នេសាទគ្រួសារក៏ត្រូវបានកែសម្រួលដែលធ្វើឲ្យប្រជាជនទូទៅ ពិសេសអ្នកប្រកបមុខរបរនេសាទជាលក្ខណៈគ្រួសារ អាចធ្វើអាជីវកម្មបានទូលំទូលាយ និងអាច ចាប់ត្រីបានច្រើន ជាងមុន។

## គ.៤ ការសម្រេចបានក្នុងការកែទម្រង់ផ្នែកព្រៃឈើ

ចំពោះផ្នែកព្រៃឈើ ក្រសួងបានយកចិត្តទុកដាក់អនុវត្តលើសកម្មភាពជាច្រើន រួមមាន ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ការបង្កើតនិងពង្រឹងសហគមន៍ព្រៃឈើ ការអនុវត្តវិធានការយ៉ាងម៉ឺងមាត់ក្នុងការគ្រប់គ្រង និងទប់ស្កាត់បទល្មើសព្រៃឈើ ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងព្រៃបម្រុងទុក ការថែរក្សាធនធានពន្ធុរុក្ខជាតិនិងសត្វព្រៃ ព្រមទាំងបោះបង្គោល ព្រំប្រទល់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ការបណ្តុះកូនឈើនៅតាមស្ថានីយ៍ផ្សព្វផ្សាយ ការដាំកូនឈើនៅតំបន់ស្តារព្រៃឈើឡើងវិញ ដែលការងារទាំងអស់នេះពិតជាបានឆ្លើយតប ទៅនឹងគោលដៅជាយុទ្ធសាស្ត្រ របស់

រាជរដ្ឋាភិបាលក្នុងកំណែទម្រង់វិស័យព្រៃឈើ។ លើសពីនេះទៀត ការបង្ក្រាបបទល្មើសព្រៃឈើ កំពុងមានសកម្មភាពមុតស្រួច ពិសេសការចូលរួមសហការយ៉ាងជិតស្និទ្ធ ជាមួយគណៈកម្មការចម្រុះ ក្នុងយុទ្ធនាការបង្ក្រាបបទល្មើស ព្រៃឈើនាពេលកន្លងមក។

គិតត្រឹមឆ្នាំ២០១៨ បានបង្កើតសហគមន៍ព្រៃឈើសរុបចំនួន ៦១៤សហគមន៍ គ្របដណ្តប់លើផ្ទៃដី៥០៨ ២០៧ ហ.ត ក្នុងនោះ ក្រសួងបានចេញប្រកាសចំនួន៤៨៤សហគមន៍ លើផ្ទៃដី ៤៣៧ ៣៧២ហ.ត និងបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន ៤៣២សហគមន៍ លើផ្ទៃដី៣៦៤ ៥៤៨ហ.ត និងបានអនុម័តផែនការគ្រប់គ្រងព្រៃ សហគមន៍ចំនួន ៨៥សហគមន៍ គ្របដណ្តប់លើផ្ទៃដីទំហំ៩៥ ៣៧១ហ.ត។ ការបង្កើតសហគមន៍ព្រៃឈើមានសន្ទុះកើនឡើងគួរឲ្យកត់សម្គាល់។

ផ្ទៃដីដាំឈើសរុបពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ សម្រេចបានចំនួន ៣៣៨ ០៤០ហ.ត ក្នុងនោះការដាំឈើជាចម្ការដោយផ្នែកឯកជន ពិសេសសម្បទានដីសេដ្ឋកិច្ចមានចំនួន ៣៣១ ៩៤៣ហ.ត។ ការកែទម្រង់លើការងារដាំឈើឡើងវិញ ត្រូវបានយកចិត្តទុកដាក់អនុវត្តយ៉ាងមានប្រសិទ្ធភាព។ ផ្អែកតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតជាគោលការណ៍ដាំឈើលើដីព្រៃចរិល ដោយសហការដៃគូជាមួយវិស័យឯកជន (លិខិតលេខ១២០សជណ.កស ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាលកម្ពុជា)។ ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសស្តីពីវិធានព្រៃឯកជន (ប្រកាសលេខ៣២៧ ប្រក.កសក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧) ដែលប្រកាសនេះ មានគោលបំណងកំណត់នូវវិធានព្រៃឯកជនសម្រាប់ជាគោលការណ៍ណែនាំក្នុងការបង្កើត និងអភិវឌ្ឍន៍ព្រៃឯកជន។

ក្រសួងបានស្នើសុំចុះបញ្ជីដីរដ្ឋ និងរៀបចំឯកសារស្នើសុំបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន ៣៨ ទីតាំង ដែលមានផ្ទៃដីសរុបទំហំ ២១១ ៩២២ហ.ត ស្ថិតក្នុងខេត្តមណ្ឌលគិរី រតនគិរី ក្រចេះ និងខេត្តស្ទឹងត្រែង។ ជារៀងរាល់ឆ្នាំ ក្រសួងតែងតែរៀបចំពិធីរុក្ខទិវា ០៩ កក្កដា ឆ្នាំ២០១៨ ដែលប្រារព្ធឡើងក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅភូមិសាស្ត្រមួយចំនួន និងបានដាំដើមឈើប្រភេទគ្រញូង ធ្នង់ កកោះ គីនីន និងឈើ ទាល។ល។ ព្រមទាំងបានដឹកប្រឡាយការពារចម្ការឈើដាំ ស្ថិតនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ និងបានបង្កើតឡូតិ៍បង្ហាញកសិ-រុក្ខកម្មនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ។

ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសព្រៃឈើពីឆ្នាំ២០១៤ដល់២០១៨ ត្រូវបានអនុវត្តយ៉ាងសកម្ម។ នៅឆ្នាំ ២០១៨ បានទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានដីព្រៃសរុបចំនួន១ ០៩៣ករណី ថយចុះ ៣៣៥ករណី បើប្រៀបធៀបឆ្នាំ២០១៧ មានចំនួន១ ៤២៨ករណី ក្នុងនោះសំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ ចំនួន៥៨២ករណី និងសំណុំរឿងបទល្មើសព្រៃឈើដែលត្រូវបញ្ជូនទៅតុលាការចំនួន៥១១ករណី។ ជាមួយគ្នានេះ រដ្ឋបាលព្រៃឈើបានចុះផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានគតិយុត្ត និងចែកឯកសារពាក់ព័ន្ធដើម្បីបង្កើនការយល់ដឹងអំពីច្បាប់ស្តីពីព្រៃឈើ។

## ក.៥. សមត្ថភាពស្ថាប័ន សេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការគ្រប់គ្រងធនធានមនុស្សតាមរយៈការសិក្សាពីតម្រូវការធនធានមនុស្សទាំងបរិមាណ និងគុណភាពដោយផ្អែកលើទំហំការងារជាក់ស្តែង ការកំណត់តួនាទីភារកិច្ច ការពិពណ៌នាការងារ ការវាយតម្លៃលើលទ្ធផលការងារ ការរៀបចំគោលនយោបាយធនធានមនុស្ស ការរៀបចំប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា ការកែទម្រង់រចនាសម្ព័ន្ធ មុខងារ និងការអនុវត្តការងារ ការចុះពង្រឹងការគ្រប់គ្រងមន្ត្រីកសិកម្ម នៅតាមបណ្តាអង្គភាពទាំងថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្តជាប់ជាប្រចាំ។ ក្នុងឆ្នាំ២០១៨ ក្រសួងមានមន្ត្រីរាជការសរុបចំនួន ៦ ៧៩៤នាក់ នារី១ ៦០៤នាក់ ស្មើនឹង ២៣% ក្នុងនោះ អង្គភាពថ្នាក់កណ្តាលមានចំនួន ២ ៨៨៣នាក់ នារី ៨១៥នាក់ ស្មើនឹង ២៨% ថ្នាក់រាជធានី ខេត្តមានចំនួន ៣ ៩១១នាក់ នារី ៧៨៩នាក់ ស្មើនឹង២០%។

ដើម្បីឆ្លើយតបទៅនឹងការកំណត់អាទិភាព "មូលធនមនុស្ស" របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការប្រកបដោយគុណវុឌ្ឍិខ្ពស់ តាមរយៈ ការបណ្តុះបណ្តាលរយៈពេលខ្លី មធ្យម និងរយៈពេលវែង ទាំងក្នុងនិងក្រៅប្រទេស។ ជាក់ស្តែង ក្នុងឆ្នាំ២០១៨ កន្លងមកនេះ ក្រសួងបានបណ្តុះបណ្តាលមន្ត្រីរាជការបានចំនួន២ ៩២៣នាក់ ក្នុងនោះមាន នារីចំនួន៦៥២នាក់។ វគ្គបណ្តុះបណ្តាលក្នុងប្រទេស សរុបបានចំនួន ២ ២៨៧នាក់ នារី ៤៦៤នាក់ ក្នុងនោះវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងមធ្យមបានចំនួន ២ ២៨០នាក់ នារីចំនួន ៤៦៣នាក់ និងបណ្តុះបណ្តាលរយៈពេលវែងបានចំនួន ០៧នាក់ នារីចំនួន ០១នាក់ (វគ្គវិក្រឹត្យការ)។ ដោយឡែកចំពោះវគ្គបណ្តុះបណ្តាលក្រៅប្រទេសសរុបបានចំនួន ៦៣៦នាក់ នារីចំនួន ១៨៨នាក់ ក្នុងនោះវគ្គបណ្តុះបណ្តាលរយៈពេលខ្លីបានចំនួន ៦១៦នាក់ នារីចំនួន ១៧៨នាក់ និងវគ្គបណ្តុះបណ្តាលរយៈពេលវែងបានចំនួន២០នាក់ នារីចំនួន១០នាក់។

ទោះបីជាយ៉ាងនេះក៏ដោយ ជាទូទៅក្រសួងមានមន្ត្រីដែលមានវិជ្ជាជីវសមស្រប តិចជាងតម្រូវការជាក់ស្តែង។ ជាលទ្ធផល សមត្ថភាពកិច្ចការរដ្ឋបាល និងបច្ចេកទេស នៅមានកម្រិត និងមានកង្វះខាតមន្ត្រីជំនាញ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួល និងការផ្លាស់ប្តូរនៃល្បឿនសេដ្ឋកិច្ចបច្ចុប្បន្ន សម្រាប់បម្រើឲ្យការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព។ ដោយសារកត្តាទាំងអស់នេះ ក្រសួងត្រូវរៀបចំផែនការ កម្មវិធីអប់រំ និងបណ្តុះបណ្តាល និងការគ្រប់គ្រងមន្ត្រីរាជការឲ្យបានសមស្របតាមតម្រូវការជាក់ស្តែង។

ការពង្រឹងសមត្ថភាពស្ថាប័នគឺជាអាទិភាពសម្រាប់កំណែទម្រង់ និងការអនុវត្ត **ផ.ក.យ.អ.វ.ក** ក៏ដូចជាការប្រើប្រាស់ និងអភិរក្សធនធានធម្មជាតិ ដូចជាព្រៃឈើនិងជលផលឲ្យមាននិរន្តរភាព។ ក្រសួងនឹងសហការគ្នាគ្រប់ផ្នែកផ្សេងៗ ដែលពាក់ព័ន្ធនឹងវិស័យកសិកម្មដូចជា វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ដែលមានជំនាញពិសេសរៀងខ្លួនឲ្យចូលរួមចំណែកក្នុងការពង្រឹងសមត្ថភាពស្ថាប័នវិស័យកសិម្មផងដែរ។ សមត្ថភាពក្នុងការអភិវឌ្ឍបច្ចេកទេស និងការផ្សព្វផ្សាយទាមទារឲ្យគ្រប់ផ្នែកពាក់ព័ន្ធចូលរួមចំណែកទៅតាមជំនាញផ្សេងៗ។ ស្ថាប័នស្រាវជ្រាវ និងអភិវឌ្ឍន៍សាកលវិទ្យាល័យ និងសាលាជាតិកសិកម្ម និងស្ថាប័នពាក់ព័ន្ធដ៏ទៃទៀត ដោយសហការជាមួយវិស័យឯកជន សង្គមស៊ីវិល និងដៃគូដ៏ទៃទៀត កំណត់អាទិភាព អភិវឌ្ឍការស្រាវជ្រាវកសិកម្ម រៀបចំផ្សព្វផ្សាយ បច្ចេកទេសតាមរបៀបទំនើបជាលក្ខណៈឌីជីថល ហើយត្រូវឲ្យ ច្បាស់ថាបច្ចេកទេសថ្មីមានលក្ខណៈសមស្រប និង បំពេញនូវតម្រូវការទីផ្សារ ព្រមទាំងជួយដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍជនបទ។

## ក.៦. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការពិនិត្យតាមដាន និងវាយតម្លៃ គឺជាតម្រូវការចាំបាច់ ដើម្បីធានាដល់ការអនុវត្តគម្រោងសកម្មភាពនិងសូចនាករនានា សម្រាប់ផ្ទៀងផ្ទាត់ជាមួយនឹងលទ្ធភាពសម្រេចបាន ដែលបានកំណត់យ៉ាងសមស្របនៅក្នុងការធ្វើផែនការ និងការរៀបចំគម្រោងសកម្មភាពនីមួយៗ។ ដូច្នេះ ការពិនិត្យតាមដាននិងវាយតម្លៃ គឺជាឧបករណ៍ដ៏ស័ក្តិសិទ្ធិសម្រាប់ផ្ទៀងផ្ទាត់រាល់សូចនាករលទ្ធផល (Outcomes & Outputs) នៅពាក់កណ្តាលអាណត្តិ និងពេញអាណត្តិ នៃការអនុវត្តផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ និងដើម្បីជាមូលដ្ឋានសម្រាប់វាយតម្លៃការអនុវត្តគោលនយោបាយតាមផ្នែក ក៏ដូចជាគោលនយោបាយថ្នាក់ជាតិ។ ទោះបីយ៉ាងណាក៏ដោយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ ក៏នឹងត្រូវបង្ហាញ និងបញ្ជាក់នូវសូចនាករជាច្រើន សម្រាប់ធ្វើការផ្ទៀងផ្ទាត់លទ្ធផលនៃការអនុវត្តផងដែរ។

ដើម្បីធានាដល់ការអនុវត្តយ៉ាងពេញលេញ នូវការពិនិត្យតាមដាននិងវាយតម្លៃ នាយកដ្ឋានផែនការនិងស្ថិតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការអនុវត្តសកម្មភាពតាមដាន និងវាយតម្លៃនេះ។ របាយការណ៍លទ្ធផលការងារសម្រាប់គម្រោងទាំងនោះ ត្រូវរៀបចំឡើងក្នុងអំឡុងពេលអនុវត្ត និងវាយតម្លៃក្រោយពេលអនុវត្ត។ បណ្តានាយកដ្ឋានអង្គភាពជំនាញនានាដែលពាក់ព័ន្ធក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ នេះបានរាយការណ៍ជូនក្រសួង (នាយកដ្ឋានផែនការ និងស្ថិតិ) ពីលទ្ធផលសម្រេចបានឲ្យបានទៀងទាត់ តាមរយៈការផ្តល់របាយការណ៍

ប្រចាំត្រីមាស និងប្រចាំឆ្នាំ។ របាយការណ៍អនុវត្ត និងសមិទ្ធផលសម្រេចបានក្នុងការអនុវត្តនេះ ត្រូវបានរៀបចំបូកសរុបដោយនាយកដ្ឋានផែនការ និងស្ថិតិ ហើយត្រូវរាយការណ៍ជូនក្រសួងពិនិត្យនិងសម្រេច។ ផ្អែកលើរបាយការណ៍ខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការបូកសរុប រួចរាយការណ៍ជូនទៅក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជាមូលដ្ឋានរាយការណ៍ជូន រាជរដ្ឋាភិបាលកម្ពុជា។

## ខ. លទ្ធផលសម្រេចបានក្នុងការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ក្រសួងបានដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់អនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពទៅតាមផ្នែកជំនាញនៃអង្គភាពថវិកាទាំង៤៥អង្គភាព ក្នុងនោះថ្នាក់កណ្តាលមានចំនួន២០អង្គភាពថវិកា និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន២៥ រាជធានី ខេត្ត។ ជាមួយគ្នានេះ ក្រសួងមានផែនការប្រមូលចំណូលមិនមែនសារពើពន្ធបង់ចូលថវិការដ្ឋទៅតាមច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨ មានទឹកប្រាក់សរុបចំនួន៤០ ៦៨១,៨លានរៀល ក្នុងនោះរដ្ឋបាលកណ្តាលចំនួន៣៨ ២៦០,៧លានរៀល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តចំនួន២ ៤២១,១លានរៀល។ ក្រសួងបានទទួលកញ្ចប់ថវិកាសម្រាប់ចំណាយក្នុងឆ្នាំ២០១៨ សរុបចំនួន២៨៥ ០០៩លានរៀល។ ថវិកានេះត្រូវបានបែងចែកសម្រាប់រដ្ឋបាលកណ្តាលចំនួន១៨១ ៧៣៧លានរៀល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តចំនួន១០៣ ២៧២លានរៀល។

ជាក់ស្តែងក្នុងឆ្នាំ២០១៨ ការអនុវត្តថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចបានលទ្ធផលដូចខាងក្រោម៖

-ក្រសួងសម្រេចអនុវត្តប្រមូលចំណូលសរុបបានចំនួន៤៣ ៥៥៦,៣លានរៀល គឺស្មើនឹង១០៧,១%ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ក្នុងនោះរដ្ឋបាលកណ្តាលអនុវត្តបានចំនួន៤០ ៤១៤,៦លានរៀល ស្មើនឹង១០៥,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨។ ការកើនឡើងនូវទឹកប្រាក់ចំណូលគឺដោយសារ (១)ចំណូលពីថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ចដែលក្រុមហ៊ុនមួយចំនួនបានបង់សងបំណុលឆ្នាំចាស់ (២)ផលពីការគ្រប់គ្រងរដ្ឋបាល ការចេញលិខិតអនុញ្ញាតពាក់ព័ន្ធជលផល នីតិកម្មកសិកម្ម និងសុខភាពសត្វនិងផលិតកម្មសត្វ (៣)ការជួលទ្រព្យសម្បត្តិរដ្ឋ (៤)ចំណូលពីការត្រួតពិនិត្យអនាម័យសាច់សត្វ និងផលដំណាំផ្សេងៗ និង(៥)ការកើនឡើងចំណូលពីការផាកពិន័យលើសេវារបស់រដ្ឋបាលជលផល ព្រៃឈើ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងនាយកដ្ឋាននីតិកម្មកសិកម្ម។ ដោយឡែកមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត អនុវត្តប្រមូលចំណូល បានចំនួន៣ ១៤១,៧ លានរៀល គឺស្មើនឹង១២៩,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨។

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តចំណាយថវិកាសរុបប្រមាណចំនួន ២៧៨ ៩៨៥,៣លានរៀល គឺស្មើនឹង៩៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុកែតម្រូវ និងស្មើនឹង៩៧,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ក្នុងនោះ ៖

**១-ផ្នែកចំណាយចរន្ត (រដ្ឋបាលកណ្តាល)**

ការអនុវត្តចំណាយសរុបចំនួន ១៣៥ ៩៥៩,១លានរៀល ស្មើនឹង៩៥,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុកែតម្រូវ និងស្មើនឹង៩៥,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

**២-ផ្នែកចំណាយចរន្ត (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត)**

ការអនុវត្តចំណាយសរុបចំនួន៩៦ ៨៨៩,៧ លានរៀល ស្មើនឹង៩៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុកែតម្រូវ និងស្មើនឹង៩៣,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

**៣-ផ្នែកចំណាយមូលធន**

ការអនុវត្តដោយអគ្គនាយកដ្ឋានកសិកម្មចំណាយសរុបចំនួន៤៦ ១៣៦,៥ លានរៀល ស្មើនឹង១០០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុកែតម្រូវ និងស្មើនឹង១១៥,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

## ៣. បញ្ហាប្រឈម

វិស័យកសិកម្មនៅមានសក្តានុពលច្រើនណាស់ ដែលយើងពុំទាន់បានប្រើប្រាស់ឲ្យអស់លទ្ធភាពនៅឡើយ។ ការអនុវត្ត ផ.យ.អ.វ.ក (២០១៤ - ២០១៨) កន្លងមក គឺត្រូវបានវាយតម្លៃថា សម្រេចបានលទ្ធផលគួរជាទីពេញចិត្ត។ ទោះបីជាយ៉ាងនេះក្តី ក៏យើងនៅជួបប្រទះបញ្ហាប្រឈមមួយចំនួនមានជាអាទិ៍៖

(១) **ផ្នែកផលិតភាពកសិកម្មនិងទីផ្សារ៖** ផលិតភាពក្នុងការដាំដុះ ក៏ដូចជាការចិញ្ចឹមសត្វ នៅមានកម្រិតទាបនៅឡើយ ដែលប្រឈមខ្លាំងក្នុងការប្រកួតប្រជែងទីផ្សារ ពិសេសថ្លៃដើមផលិតកម្មរបស់កសិករនៅមានកម្រិតខ្ពស់។ ម៉្យាងវិញទៀត ការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ គុណភាពនៃធាតុចូលកសិកម្ម និងសេវាផ្នែកកសិកម្មនៅថ្នាក់មូលដ្ឋាន ពិសេសថ្នាក់ស្រុកនៅមានកម្រិត។ ការបន្សុំារបស់កសិករទៅនឹងការប្រែប្រួលអាកាសធាតុការផ្សព្វផ្សាយបច្ចេកទេស តាមផ្នែកនីមួយៗ និងការផ្តល់សេវាព័ត៌មានទីផ្សារកសិផលទៅដល់កសិករ គឺនៅមិនទាន់មានភាពទូលំទូលាយ។ ម៉្យាងទៀត កសិករតែងជួបប្រទះនូវការធ្លាក់ចុះនៃតម្លៃកសិផលក្រោយពេលប្រមូលផល ហើយការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាក៏នៅពុំទាន់បានល្អប្រសើរ។ ការគ្រប់គ្រង និងការប្រើប្រាស់ដីកសិកម្មឲ្យចំគោលដៅ និងសក្តានុពលនៅតាមភូមិសាស្ត្រនីមួយៗស្ថិតនៅតែជាបញ្ហា ដែលក្រសួងកំពុងគិតគូរអំពីការកំណត់តំបន់ដាំដុះកសិកម្មឲ្យបានសមស្រប។ លើសពីនេះទៀត អត្រាការប្រាក់ខ្ពស់ និងការទទួលបានហិរញ្ញប្បទាននៅមានកម្រិត ដែលជាហេតុនាំឲ្យប៉ះពាល់ដល់ថ្លៃដើមផលិត។

(២) **ផ្នែកហេដ្ឋារចនាសម្ព័ន្ធនិងភស្តុភារកម្ម** (Logistics)៖ ប្រព័ន្ធស្រោចស្រពកសិកម្មនៅពុំទាន់បានគ្របដណ្តប់លើផ្ទៃដីដាំដុះឲ្យបានទូលំទូលាយ ជាពិសេស ការរៀបចំប្រព័ន្ធប្រឡាយបង្ហូរទឹកចូលស្រែដោយស្វ័យប្រវត្តិពុំទាន់បានពង្រីកដល់ដីស្រែរបស់កសិករនៅឡើយ។ បញ្ហាតម្លៃដឹកជញ្ជូន អគ្គិសនី និងប្រព័ន្ធសេវាភស្តុភារ គឺជាបញ្ហាមួយដែលរួមចំណែកធ្វើឲ្យថ្លៃដើមផលិតកម្មខ្ពស់។ ការកង្វះធនធានក្នុងការស្តារ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការបង្កើនផលិតភាពលើសក្តានុពលដីធ្លី និងស្រែចម្ការរបស់កសិករក៏ត្រូវតែមានវិធានការដោះស្រាយនាពេលខាងមុខ។

(៣) **ផ្នែកស្រាវជ្រាវបច្ចេកវិទ្យា និងបច្ចេកទេសកសិកម្ម៖** ការងារស្រាវជ្រាវ និងការផ្តល់សេវាបច្ចេកទេសកសិកម្មនៅមានកម្រិត ហើយសមត្ថភាពទទួលយកចំណេះដឹងអំពីបច្ចេកទេសដាំដុះ ចិញ្ចឹមសត្វ និងវារីវប្បកម្ម ព្រមទាំងការប្រើប្រាស់ធាតុចូលកសិកម្មសមស្របតាមបទដ្ឋានបច្ចេកទេស ក៏ដូចជាក្នុងការកែច្នៃផលិតផលរបស់ប្រជាកសិករក៏នៅមានកម្រិត ដែលបានជះឥទ្ធិពលដល់ថ្លៃដើមផលិតខ្ពស់ ពិបាកប្រជែងនៅលើទីផ្សារ។ ការវិនិយោគក្នុងផ្នែកអប់រំ ស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មនៅមានទំហំតូច ដែលត្រូវតែមានការយកចិត្តទុកដាក់ខ្ពស់។

(៤) **ការបង្ក្រាបបទល្មើស៖** បទល្មើសព្រៃឈើ ជលផល ការលួចនាំចូលនិងនាំចេញសត្វ សម្ភារកសិកម្មដោយខុសច្បាប់នៅតែកើតមាន ជាពិសេសបណ្តាខេត្តជាប់ព្រំដែន។ សកម្មភាពកាប់រានហ៊ុមព័ទ្ធដីព្រៃឈើ ការរានដីព្រៃលិចទឹកដោយខុសច្បាប់ គឺនៅតែកើតមានពុំចេះចប់រហូតមកទល់បច្ចុប្បន្ននេះ។

## ៤. វិធានការ

### គោលនយោបាយសម្រាប់រួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ៖

គោលនយោបាយអភិវឌ្ឍន៍កសិកម្មរបស់រាជរដ្ឋាភិបាល ត្រូវបានកំណត់ច្បាស់លាស់លើការលើកកម្ពស់វិស័យកសិកម្មឱ្យក្លាយទៅជាផ្នែកនាំមុខមួយ ដែលអាចផ្តល់ចលករបន្ថែមដល់កំណើនសេដ្ឋកិច្ច និងអាចចូលរួមវិភាគទានយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ។ ក្នុងទិសដៅនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបង្កើន ការអនុវត្តប្រពលវប្បកម្មកសិកម្ម ការបង្កើនសមត្ថភាពបច្ចេកទេសកសិកម្មដល់កសិករ សហគមន៍កសិកម្ម ផ្តល់ហេដ្ឋារចនាសម្ព័ន្ធបម្រើឲ្យផលិតកម្មកសិកម្ម សម្របសម្រួល ដោះស្រាយបញ្ហាទីផ្សារ និងបង្កើនការកែច្នៃកសិផល ជាពិសេសការកែច្នៃសម្រាប់ការនាំចេញ។

ជាមួយគ្នានេះដែរ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានផ្តោតការយកចិត្តទុកដាក់លើវិស័យអាទិភាព ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម មានដូចខាងក្រោម៖

ទី១-បន្តលើកកម្ពស់ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍បច្ចេកវិទ្យា និងបច្ចេកទេសកសិកម្មទំនើប ក្នុងទិសដៅបង្កើន បរិមាណ គុណភាព អាហារូបត្ថម្ភ និងពិពិធកម្មផលិតផលកសិកម្មប្រកបដោយនិរន្តរភាពធន់នឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការទីផ្សារក្នុង និងក្រៅប្រទេស។ យកចិត្តទុកដាក់អភិវឌ្ឍធនធានមនុស្ស និងជាពិសេស បង្កើនចំនួនអ្នកស្រាវជ្រាវ និងអ្នកវិទ្យាសាស្ត្រកសិកម្មឲ្យបានច្រើន ដោយផ្តល់ការលើកទឹកចិត្តដល់អ្នកស្រាវជ្រាវ និង អ្នកវិទ្យាសាស្ត្រជាចាំបាច់។ ត្រូវធ្វើកសិកម្មចម្រុះប្រកបដោយភាពវៃឆ្លាត មិនត្រូវធ្វើតែដំណាំស្រូវមួយមុខ ឬការធ្វើតាមគ្នា ដោយមិនបានវិភាគឲ្យបានស៊ីជម្រៅនោះឡើយ។ ទន្ទឹមនឹងនេះ ត្រូវយកចិត្តទុកដាក់ជំរុញការប្រើប្រាស់បច្ចេកវិទ្យាកសិកម្ម ថ្មីៗ ប្រកបដោយនវានុវត្តន៍ មានជាអាទិ៍ ការអនុវត្តកសិកម្មល្អ ការកែលម្អការគ្រប់គ្រង និងប្រើប្រាស់ធនធានដីប្រកបដោយ ចីរភាព ការកែលម្អប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងទឹក ការប្រើប្រាស់យន្តូបនីយកម្មកសិកម្ម និងបច្ចេកវិទ្យាក្រោយ ប្រមូលផល ការបង្កើនភាពធន់នឹងអាកាសធាតុ និងគ្រោះ ធម្មជាតិ ការលើកកម្ពស់គុណភាពនៃការផ្តល់សេវាផ្សព្វផ្សាយ កសិកម្ម ឲ្យបានទៅដល់សហគមន៍កសិកម្ម ព្រមទាំងពង្រឹង ការគ្រប់គ្រង និងត្រួតពិនិត្យពូជដំណាំកសិកម្ម និងធាតុចូល កសិកម្មរួមទាំង ការកែលម្អពូជសត្វ ការពង្រឹងសមត្ថភាព មន្ទីរពិសោធន៍ជាតិ កសិដ្ឋានផលិតពូជ ស្ថានីយ និងមជ្ឈមណ្ឌល ស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មឲ្យបានល្អប្រសើរ។ ត្រូវជំរុញការរៀបចំកសាងលិខិតបទដ្ឋានគតិយុត្ត និងច្បាប់ពាក់ព័ន្ធ នឹងវិស័យកសិកម្ម ព្រមទាំងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍តាមអនុវិស័យនីមួយៗ។

ទី២- ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម និងសហគមន៍អ្នកចិញ្ចឹមសត្វដែលបានចុះបញ្ជីរួចហើយ ឲ្យមាន លក្ខណៈជាពាណិជ្ជកម្ម ដោយជំរុញឲ្យអនុវត្តបច្ចេកវិទ្យាសមស្រប ការផ្គត់ផ្គង់និងសន្សំសំចៃទឹកនៅតាមសហគមន៍ កសិកម្ម និងអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ព្រមទាំងលើកកម្ពស់ការចូលរួមវិនិយោគពីវិស័យឯកជនក្នុងគ្រប់ខ្សែច្រវាក់តម្លៃ កសិកម្ម តាមអភិក្រមភាពជាដៃគូរវាង "រដ្ឋ- ឯកជន និងផលិតករ" ឲ្យមានលក្ខណៈប្រទាក់ក្រឡាគ្នាក្នុងការ រកទីផ្សារបន្ថែម សម្រាប់ផលិតផលកសិកម្មជាអាទិភាព។ លើសពីនេះទៀត ត្រូវពិនិត្យមើលលទ្ធភាពធ្វើយ៉ាងណាឲ្យសហគមន៍អាចទទួល បានផលប្រយោជន៍ និងមានចំណូលសម្រាប់ដំណើរការអភិវឌ្ឍរបស់ខ្លួនប្រកបដោយភាពម្ចាស់ការ។ ទន្ទឹមនឹងនេះ ត្រូវបន្ត សហការជាមួយដៃគូអភិវឌ្ឍន៍នានា និងស្វែងរកដៃគូថ្មីៗទៀត ដើម្បីអនុវត្តគម្រោងបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីជំនាញ និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍សហគមន៍ ព្រមទាំងជំរុញនិងរួមគ្នាធ្វើការអប់រំ ផ្សព្វផ្សាយ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានឲ្យយល់ដឹងជាសាធារណៈ អំពីការអភិវឌ្ឍវិស័យកសិកម្ម។

ទី៣- ពង្រឹង និងពង្រីកសហគមន៍កសិករកៅស៊ូគ្រួសារ ដើម្បីបង្កើនកាលានុវត្តភាពក្នុងការការពារផលប្រយោជន៍ របស់កសិករ ទាំងការដាំដុះ ការយកផល ការកែច្នៃ ព្រមទាំងអំណាចនៃការចរចាថ្លៃនៅពេលលក់ផលិតផលទាំងនោះ។ ជំរុញការវិនិយោគលើការកែច្នៃផលិតផលកៅស៊ូ ដើម្បីបង្កើនតម្លៃបន្ថែម បង្កើតការងារ ចូលរួមកាត់បន្ថយភាពក្រីក្រនៅ ជនបទ។ ជាមួយគ្នានេះ ត្រូវពិនិត្យ និងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូធម្មជាតិ ប្រកបដោយនិរន្តរភាព។

ទី៤- ជំរុញការធ្វើពិពិធកម្មកសិកម្មទៅរកផលិតផលដែលមានតម្លៃបន្ថែមខ្ពស់ និងមានសក្តានុពលលើដំណាំ ការចិញ្ចឹមសត្វ វារីវប្បកម្ម ផលិតផលឈើដាំ និងការវិនិយោគលើការកែច្នៃកសិផលសំខាន់ៗ ដោយត្រូវបន្តលើកកម្ពស់ គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ការកែច្នៃវេចខ្ចប់ និងពង្រឹងសមត្ថភាពពិសោធន៍ ស្តង់ដារគុណភាព ក៏ដូចជា ពង្រឹងវិធានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ (SPS) តាមរយៈការចរចាជាមួយបណ្តាប្រទេសដែលទិញ ផលិតផលកសិកម្មពីកម្ពុជា ការរៀបចំពិធីសារស្តីពីការនាំចេញផលិតផលកសិកម្មកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ។

ទី៥- ជំរុញការចិញ្ចឹមសត្វរបស់កសិករឲ្យទៅជាការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្ម ជាពិសេសការចិញ្ចឹម គោពូជកូនកាត់ ដើម្បីបង្កើនប្រាក់ចំណូល ព្រមទាំងលើកទឹកចិត្តដល់ការចិញ្ចឹមសត្វខ្នាតតូច មធ្យម និងខ្នាតធំដែល

មានផលិតភាពខ្ពស់ ប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងបង្កើនសមត្ថភាពប្រកួតប្រជែងសម្រាប់ការនាំចេញ។ គ្រប់គ្រងការធ្វើអាជីវកម្មសត្វរស់ ផលិតផលសត្វ ចំណីសត្វ បសុឱសថ និងធាតុចូលផ្សេងៗ ដោយមិនឲ្យមានការធ្វើអាជីវកម្មផ្តាច់មុខដែលប៉ះពាល់ដល់តម្លៃ និងបញ្ហាទីផ្សារ។ ត្រូវជំរុញការកែច្នៃផលិតផលសាច់ ដោយត្រូវគ្រប់គ្រងសត្តឃាតដ្ឋាន កន្លែងពិឃាតសត្វ និងកន្លែងកែច្នៃ ឲ្យអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល និងមានការត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វ ធានាបាននូវគុណភាព អនាម័យ និងសុវត្ថិភាពសាច់សម្រាប់ធានាតម្រូវការក្នុងស្រុក និងឆ្ពោះទៅរកការនាំចេញទៅបរទេស។ ជាមួយគ្នានេះ ត្រូវពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ ដើម្បីបង្ការការពារជំងឺឆ្លងរាលដាលសត្វ ផលិតផលសត្វប្រកបដោយសុវត្ថិភាព និងគ្រប់គ្រងហានីភ័យជំងឺរាតត្បាតនានាជាយថាហេតុ។ ព្រមជាមួយនោះ ត្រូវពង្រឹងការអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងត្រូវរៀបចំកសាងលិខិតបទដ្ឋានក្រោមច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់។

ទី៦- បង្កើតស្ថានីយ៍ចត្តាឡីស័ក ដំណាំ សត្វ និងជលផល នៅតាមតំបន់សំខាន់ៗ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលសមាសធាតុចង្រៃ ជំងឺសត្វ និងជំងឺស៊ូណូស ជំងឺត្រី និងទប់ស្កាត់ការនាំចូល នាំចេញ ឆ្លងកាត់នូវផលិតផលកសិកម្មខូចគុណភាព ដែលនាំឲ្យប៉ះពាល់ដល់សុខភាពសាធារណៈ និងខូចទីផ្សារក្នុងស្រុក និងនាំចេញ។ ជំរុញឱ្យក្រសួងស្ថាប័នពាក់ព័ន្ធ ពិសេសរដ្ឋបាលខេត្តនៅជាប់ព្រំដែន ត្រូវសហការឲ្យមានលក្ខណៈប្រទាក់ក្រឡាគ្នាក្នុងការគ្រប់គ្រងឲ្យមានប្រសិទ្ធភាព ព្រមទាំងក្តាប់ឲ្យបាននូវព័ត៌មាន និងទិន្នន័យនៃការនាំចូល និងនាំចេញផលិតផលកសិកម្មពីបណ្តាប្រទេសជិតខាង ដើម្បីធានានូវការគ្រប់គ្រងផលស្តុកក្នុងស្រុក និងផលប៉ះពាល់ទីផ្សារក្នុងតំបន់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

ទី៧- ពង្រឹងសមត្ថភាពរបស់សហគមន៍នេសាទឲ្យបានរឹងមាំ ក្លាយជាសហគមន៍នេសាទគ្មានបទល្មើសជលផលទាំងទឹកសាបនិងសមុទ្រ។ ជាមួយគ្នានេះ ត្រូវជំរុញការអភិវឌ្ឍវារីវប្បកម្មគ្រប់ប្រភេទទៅតាមស្ថានភាពជាក់ស្តែង ព្រមទាំងត្រូវបន្តពង្រឹងការគ្រប់គ្រង និងការពារកន្លែងអភិរក្សជលផលឱ្យមានប្រសិទ្ធភាពខ្ពស់ ពិសេសត្រូវថែរក្សាការពារព្រៃលិចទឹក និងព្រៃកោងកាងឱ្យបានគង់វង្ស ដែលជាជម្រកដ៏សំខាន់របស់មច្ឆជាតិ។ លើសពីនេះទៀត បន្តចូលរួមធ្វើវិសោធនកម្មច្បាប់ស្តីពីជលផល និងត្រូវខិតខំរៀបចំលិខិតបទដ្ឋានគតិយុត្ត ជំរុញការអនុវត្តអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ដើម្បីប្រយុទ្ធប្រឆាំងការនេសាទល្មើសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ (IUU Fishing) ដោយត្រូវបង្កើតយន្តការថ្នាក់ជាតិឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា ជាមួយអន្តរស្ថាប័នស្របតាមនីតិវិធីជាធរមាន។

ទី៨- រៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ព្រៃផ្តល់ផល ដើម្បីឆ្លើយតបទៅនឹងបរិបទកំណែទម្រង់បច្ចុប្បន្ន សំដៅធានាបានស្ថិរភាពរឹងមាំលើការអភិវឌ្ឍអនុវិស័យព្រៃឈើជាតិយូរអង្វែង។ បន្ថែមលើនេះ ត្រូវបន្តពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើ ដោយជួយប្រជាសហគមន៍ជនបទឱ្យបង្កើនចំណូល លើកកម្ពស់ជីវភាពរស់នៅតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម។ ក្នុងគោលដៅពង្រីកគម្របព្រៃឈើ ត្រូវបន្តជំរុញការស្តារដាំដុះព្រៃឈើឡើងវិញនៅលើដីព្រៃរេចរិល ដីព្រៃរងការធ្វើអាជីវកម្ម ដីទំនេររបស់រដ្ឋ និងដីព្រៃដែលបានដកហូតពីសម្បទានដីសេដ្ឋកិច្ច ដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយ សម្រាប់ចែកចាយជូនប្រជាពលរដ្ឋដាំដុះ។ ជាមួយគ្នានេះ ត្រូវរៀបចំបង្កើតសួនរុក្ខសាស្ត្រ (Botanical Garden) នៅតាមតំបន់អេកូឡូស៊ីរុក្ខជាតិកម្ពុជា ក្នុងគោលបំណងអប់រំបណ្តុះបណ្តាល និងផ្សព្វផ្សាយនូវប្រភេទរុក្ខជាតិមានដោយកម្រ និងជិតផុតពូជ ព្រមទាំងដាក់តាំងបង្ហាញនូវសំណាកប្រភេទរុក្ខជាតិសំខាន់ៗ ប្រភេទគ្រួសារ និងអំបូរដទៃទៀត ដោយប្រើប្រាស់ប្រភពថវិកាមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ និងពីប្រភពផ្សេងៗទៀត។ សហការជាមួយគណៈបញ្ជាការឯកភាពរាជធានី ខេត្ត ដើម្បីចូលរួមឱ្យបានល្អ ក្នុងការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងការកាប់រានដីព្រៃឈើឱ្យមានប្រសិទ្ធភាព។ តំបន់សម្បទានសេដ្ឋកិច្ច ដែលនៅសេសសល់ពីមុនមកនឹងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដ៏តឹងរឹង ដើម្បីធានាថា ដំណើរការដីសម្បទានសេដ្ឋកិច្ចទាំងនោះប្រព្រឹត្តទៅប្រកបដោយចីរភាព និងប្រសិទ្ធភាព

ខ្ពស់។ ព្រមជាមួយនោះ ត្រូវចូលរួមធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងរៀបចំកសាងលិខិតបទដ្ឋានក្រោមច្បាប់ ព្រមទាំងពង្រឹងការអនុវត្តច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់។

ទី៩- បន្តចុះស្រាវជ្រាវ រុករក និងបង្ក្រាបបទល្មើសព្រៃឈើ ជលផល ការកាប់រាន ដុត ឈូសឆាយដីព្រៃឈើ និងព្រៃលិចទឹកយកដីធ្វើកម្មសិទ្ធិតាមគ្រប់រូបភាព ដោយប្រើប្រាស់កម្លាំងចម្រុះ អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ អង្គភាពពាក់ព័ន្ធ និងតុលាការ ព្រមទាំងបន្តយកចិត្តទុកដាក់ជំរុញការបោះបង្គោលព្រំព្រៃឈើ និងព្រៃលិចទឹកឱ្យបានឆាប់រហ័ស ដើម្បីទប់ស្កាត់ និងកាត់បន្ថយឱ្យបានជាអតិបរមានូវការរំលោភបំពានលើដីព្រៃឈើ និងព្រៃលិចទឹកជាដើម។

ទី១០- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង និងបណ្តាប្រទេសដៃគូអភិវឌ្ឍន៍នានា ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់និងអន្តរជាតិ ដើម្បីស្វែងរកជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសថ្មីៗ សម្រាប់ការធ្វើទំនើបភាវូបនីយកម្មកសិកម្ម ព្រមទាំងខិតខំបង្កើនកិច្ចសហប្រតិបត្តិការ និងធ្វើការចរចាដើម្បីស្វែងរកទីផ្សារសម្រាប់ការនាំចេញផលិតផលកសិកម្មឱ្យបានទូលំទូលាយជាមួយប្រទេសនានាក្នុងបរិបទនៃសាកលភាវូបនីយកម្ម។ លើកទឹកចិត្តដល់អ្នកវិនិយោគទុនពីខាងក្នុង និងក្រៅប្រទេស បង្កើនទុនវិនិយោគក្នុងវិស័យកសិកម្មលើគ្រប់ខ្សែច្រវាក់តម្លៃកសិកម្ម ពិសេសការកែច្នៃផលិតផលកសិកម្ម ដើម្បីផ្សារភ្ជាប់កសិករ ឬសហគមន៍កសិកម្មទៅនឹងទីផ្សារតាមអភិក្រមភាពជាដៃគូរវាងរដ្ឋ ឯកជន និងអ្នកផលិត។ ទន្ទឹមនឹងនេះ ត្រូវជំរុញដល់ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ-អន្តរជាតិទាំងអស់ ឱ្យបន្តគាំទ្រការលើកកម្ពស់ និងជំរុញ ការអភិវឌ្ឍវិស័យកសិកម្មតាមគ្រប់រូបភាព ដើម្បីធានាឲ្យមានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទាំងនៅក្នុងកម្រិត គ្រួសារ សហគមន៍ និងថ្នាក់ជាតិ។ ជាមួយគ្នានេះ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងអនុវិស័យ នៃវិស័យកសិកម្ម នឹងត្រូវជំរុញរៀបចំ និងដាក់ឲ្យអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

## II. គោលបំណងគោលនយោបាយ

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៃនីតិកាលទី៦នៃរដ្ឋសភា ដោយបានកំណត់នូវគោលដៅជាយុទ្ធសាស្ត្រ៤ និងវិស័យអាទិភាព៤ ដើម្បីឆ្លុះបញ្ចាំងពីការប្តេជ្ញា ចិត្តក្នុងការបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណនេះ។ គោលដៅជាយុទ្ធសាស្ត្រ៤ របស់រាជរដ្ឋាភិបាលត្រូវបានកំណត់រួមមាន៖ (ទី១) ធានាឲ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំ៧% ប្រកបដោយចីរភាព និងធន់នឹងវិបត្តិតាមរយៈ ការធ្វើពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ចថ្មីៗដោយទូលំទូលាយ និងមានភាពប្រកួតប្រជែង ជាមួយនឹងការថែរក្សាស្ថិរភាព ម៉ាក្រូសេដ្ឋកិច្ចតាមរយៈការគ្រប់គ្រងអត្រាអតិផរណាឲ្យនៅទាប ធានាស្ថិរភាព អត្រាប្តូរប្រាក់ ការខិតខំបង្កើនទុន បម្រុងជាប្រចាំ និងការគ្រប់គ្រងបំណុលសាធារណៈដោយគត់មត់ (ទី២)បង្កើតការងារឲ្យបានកាន់តែច្រើនទាំង បរិមាណ និងគុណភាព ជូនដល់ប្រជាជនកម្ពុជា ជាពិសេស សម្រាប់ស្រទាប់យុវជន តាមរយៈការផ្តល់ជំនាញព័ត៌មានទីផ្សារការងារ ការកែសម្រួលលក្ខខណ្ឌការងារ ការលើកកម្ពស់ សកម្មភាពធុរកិច្ច និងការជម្រុញការវិនិយោគ ទាំងក្នុងប្រទេស និងក្រៅប្រទេស (ទី៣)សម្រេចឲ្យបាននូវគោលដៅ នៃការកាត់បន្ថយភាពក្រីក្រ ឲ្យស្ថិតនៅក្រោម អត្រាទាបជាង១០% ការពារមិនឲ្យភាពក្រីក្រវិលត្រឡប់មកវិញ ដោយផ្តោតលើការលើក កម្ពស់លើការងារចូលរួម ក្នុងយន្តការទីផ្សារ ការអនុវត្តគោលនយោបាយគាំពារសង្គម ការកាត់បន្ថយបន្ទុកជីវភាពរស់នៅ និងការផ្តល់សេវាសាធារណៈ ប្រកបដោយគុណភាព និងការកាត់បន្ថយគម្លាតសង្គម និង(ទី៤)បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ សំដៅបម្រើប្រជាជន ឲ្យកាន់តែប្រសើរឡើង។

ដើម្បីសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រ និងវិស័យអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់គោលនយោបាយរួមមួយរបស់ខ្លួន ដើម្បីចូលរួមចំណែកក្នុងកំណើន ការងារ

សមធម៌ និងប្រសិទ្ធភាព សំដៅសម្រេចឲ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ កម្រិតជីវភាព របស់ប្រជាពលរដ្ឋ។ គោលនយោបាយរួមរបស់វិស័យកសិកម្ម គឺដូចខាងក្រោម៖

*"ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ ព្រមទាំងបង្កើន ប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព"។*

នៅក្នុងគោលនយោបាយរួមនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដាក់ចេញនូវគោលបំណង គោលនយោបាយជាគន្លឹះអាទិភាពចំនួន២គឺ៖

គោលបំណងគោលនយោបាយទី១៖ "បង្កើនផលិតភាព ពិពិធកម្មកសិកម្ម ការប្រកួតប្រជែង និងពាណិជ្ជូបនីយកម្មកសិកម្ម"។

គោលបំណងគោលនយោបាយទី២៖ "បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព"។

| គោលបំណង គោលនយោបាយ | មុំនៃយុទ្ធសាស្ត្រចតុកោណ នៅក្នុង ជ.យ.អ.៩ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម នៅក្នុង ជ.យ.អ.៩ |
|---|---|---|
| "ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផល មានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព" | មុំទី១ នៃយុទ្ធសាស្ត្រចតុកោណ | ការលើកស្ទួយវិស័យកសិកម្ម និងអភិវឌ្ឍជនបទ |
| | មុំទី២ នៃយុទ្ធសាស្ត្រចតុកោណ | ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ដោយចីរភាព |
| | មុំទី៤ នៃយុទ្ធសាស្ត្រចតុកោណ | ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ |

## III. កម្មវិធី/យុទ្ធសាស្ត្រអាទិភាព

### ក. កម្មវិធីនិងយុទ្ធសាស្ត្រអាទិភាព

ដើម្បីធ្វើឱ្យសម្រេចបានគោលបំណងគោលនយោបាយ និងយុទ្ធសាស្ត្រអាទិភាពខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំកម្មវិធីអាទិភាពសំខាន់ៗចំនួនប្រាំ ដែលជាផ្នែកមួយនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ សំដៅពង្រឹងការអនុវត្តថវិកាតាមកម្មវិធី និងកម្មវិធីវិនិយោគសាធារណៈ។ កម្មវិធីថ្មីទាំង៥នោះរួមមាន ៖

***កម្មវិធីទី-១÷ ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច***

***កម្មវិធីទី-២÷ ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ***

***កម្មវិធីទី-៣÷ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម***

***កម្មវិធីទី-៤÷ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ***

***កម្មវិធីទី-៥÷ ការបង្កើនប្រសិទ្ធភាព សេវាគាំទ្រ និងការអភិវឌ្ឍធនធានមនុស្ស***

## រចនាសម្ព័ន្ធកម្មវិធីក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣



ដោយផ្អែកលើរចនាសម្ព័ន្ធផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣ ក្រសួងបានពង្រាងនូវកម្មវិធីចំនួន៥ ដោយកម្មវិធីនីមួយៗមានគោលបំណងច្បាស់លាស់ សម្រាប់តម្រង់ទិសក្នុងការអនុវត្តក្នុងរយៈពេល ៥ឆ្នាំខាងមុខ (២០១៩-២០២៣) ដែលគោលបំណងនៃកម្មវិធីទាំង៥ នឹងត្រូវបានកំណត់ដូចខាងក្រោម៖

## កម្មវិធីទី-១៖ ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច

<u>គោលបំណងកម្មវិធីទី១÷</u> "ជំរុញកំណើនផលិតកម្មគ្រប់មុខដំណាំក្នុងរង្វង់៥% និងបង្កើនការនាំចេញផលិតផលដំណាំកសិកម្ម៧% ក្នុងមួយឆ្នាំ ដោយពង្រីកទំនើបកម្មកសិកម្ម បង្កើនផលិតភាព ពិពិធកម្មដំណាំដែលមានសក្តានុពល និងការប្រកួតប្រជែងទីផ្សារខ្ពស់"។

ដើម្បីសម្រេចនូវគោលដៅសូចនាករនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងជំរុញវិធានការគោលនយោបាយសំខាន់ៗដូចខាងក្រោម៖

- **ជំរុញផលិតកម្ម និងផលិតភាពដំណាំដែលមានសក្តានុពលទីផ្សារខ្ពស់**
  - ជំរុញការបង្កើនផលិតភាព ពិពិធកម្មកសិកម្ម លើមុខដំណាំដែលមានផលចំណេញខ្ពស់ និងមានតម្រូវការទីផ្សារ បង្កើនគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្ម ដោយត្រូវអនុវត្តផលិតកម្មកសិកម្មសរីរាង្គ ឬការអនុវត្តកសិកម្មល្អ (Good Agriculture Practice-GAP) ប្រកបដោយភាពវៃឆ្លាត រួមនឹងការបញ្ចូលនូវបច្ចេកវិទ្យាទំនើបឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយ
  - បន្តការលើកកម្ពស់យន្តនីយកម្មកសិកម្មតាមរយៈ (១)ការជំរុញការប្រើប្រាស់គ្រឿងយន្តកសិកម្ម (២)ការបង្កើតមជ្ឈមណ្ឌលថែទាំ ការអភិវឌ្ឍវិស្វកម្មកសិកម្ម ស្រាវជ្រាវ ផលិតឧបករណ៍ដើម្បីបំពាក់ ក្នុងកសិដ្ឋានគំរូ និង(៣)ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាប្រកបដោយភាពច្នៃប្រឌិតខ្ពស់នៅក្នុងគ្រប់ដំណាក់ ខ្សែផលិតកម្មកសិកម្ម ដើម្បីធានាបាននូវគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់ កាត់បន្ថយ ជាអតិបរមាដល់ការហូរច្រោះខូចគុណភាពដី ការខ្វះខាតថាមពល ទឹក និងការបាត់បង់ផលដែលផលិតបាន
  - បន្តជំរុញការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម ប្រកបដោយចីរភាព តាមរយៈការទប់ស្កាត់បញ្ហាខិន ភាពដី ការកំណត់តំបន់ដាំដុះ ការកែលម្អជីជាតិដី ដោយបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យផែនទីកំណត់តំបន់ដាំដុះ សម្រាប់ប្រើប្រាស់ដីកសិកម្មប្រកបដោយប្រសិទ្ធភាព និងការបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុក្នុង គោលបំណងជំរុញផលិតកម្មកសិកម្ម ពិសេសដំណាំទៅតាមតំបន់មានសក្តានុពល និងទាក់ទាញវិនិយោគទុនឲ្យស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥
  - ជំរុញការអភិវឌ្ឍដំណាំស្រូវ តាមរយៈការស្រាវជ្រាវ និងការបណ្តុះបណ្តាលអំពីការពង្រឹងគុណភាពពូជ និង លើកកម្ពស់បច្ចេកទេសដាំដុះប្រកបដោយគុណភាព ប្រសិទ្ធភាពសេដ្ឋកិច្ច និងនិរន្តរភាពផលិតកម្ម ដោយសហការជាមួយស្ថាប័ន និងអង្គភាពជំនាញពាក់ព័ន្ធ
  - បន្តការអភិវឌ្ឍ ការលើកកម្ពស់គុណភាព ផលិតភាព និងបរិមាណ ព្រមទាំងស្តង់ដារូបនីយកម្មដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម តាមរយៈកិច្ចសហប្រតិបត្តិការស្រាវជ្រាវជាមួយស្ថាប័នជាតិនិងអន្តរជាតិ ការផ្តល់សេវាបច្ចេកទេសដល់កសិករ និងសហគមន៍កសិកម្ម ព្រមទាំងសម្របសម្រួលការជំរុញការផលិតស្របតាមតម្រូវការទីផ្សារ។
- **លើកកម្ពស់ការការពារដំណាំ គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម**
  - បន្តពង្រឹងនិងជំរុញការងារផ្សព្វផ្សាយកសិកម្ម ការប្រើប្រាស់យន្តការផ្សព្វផ្សាយតាមលក្ខណៈពហុនិយមលើការផ្ទេរបច្ចេកវិទ្យា ការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានវិទ្យា ដល់អ្នកប្រើប្រាស់បានទាន់ពេលវេលា និងសមស្របទៅតាមតម្រូវការ
  - បន្តពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍន៍អាជីវកម្មមុខរបរសហគមន៍កសិកម្ម ដើម្បីឲ្យក្លាយទៅជាសហគ្រាសសេដ្ឋកិច្ចកសិកម្មជនបទរឹងមាំមួយ តាមរយៈការបណ្តុះបណ្តាល ការពង្រឹងសមត្ថភាព ការរៀបចំវេទិកា

ធុរៈកិច្ចសហគមន៍កសិកម្ម ការផ្ដល់អនុសាសន៍លើការងារដឹកនាំនិងគ្រប់គ្រង និងការវាយតម្លៃសមត្ថភាពសហគមន៍កសិកម្ម

- ពង្រឹងការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យ (SPS) តាមរយៈការពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងពង្រឹងសមត្ថភាពមន្ត្រីភូតគាមអនាម័យនៅតាមទីស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ តាមច្រកទ្វារព្រំដែន ដើម្បីធានានូវប្រសិទ្ធភាពក្នុងការត្រួតពិនិត្យ និងមានការទទួលស្គាល់ជាអន្តរជាតិ
- ពង្រឹងនិងអភិវឌ្ឍសមត្ថភាពមន្ទីរពិសោធន៍ជាតិកសិកម្ម តាមរយៈការជំរុញយន្តការវិភាគគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម។

➢ **លើកកម្ពស់សេវាផ្សព្វផ្សាយកសិកម្ម និងអភិវឌ្ឍន៍សហគមន៍កសិកម្ម**

- ពង្រឹងនិងជំរុញការងារផ្សព្វផ្សាយកសិកម្ម ពិសេសការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានវិទ្យាសំដៅបង្កើនចំនួនអ្នកប្រើប្រាស់ កសិករ សហគមន៍កសិកម្ម ឲ្យទទួលបាននូវឯកសារបច្ចេកទេសវិទ្យាសាស្ត្រថ្មីៗ ស្របតាមការរីកចម្រើននៃវិស័យកសិកម្ម
- ពង្រឹង និងជំរុញការអភិវឌ្ឍសហគមន៍កសិកម្ម ដើម្បីធ្វើឲ្យសហគមន៍ជាកន្លែងផលិតទ្រង់ទ្រាយធំ ដោយភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យាដែលជាគន្លឹះក្នុងការដោះស្រាយទីផ្សារកសិផល
- ពង្រឹងសមត្ថភាពសហគមន៍កសិកម្មដែលបានចុះបញ្ជីរួច ឲ្យមានលក្ខណៈជាជំនាញ អាជីព ដោយជំរុញឲ្យអនុវត្តបច្ចេកវិទ្យាសមស្រប ការផ្គត់ផ្គង់ និងសន្សំសំចៃទឹកនៅតាមសហគមន៍កសិកម្មការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា និងលើកកម្ពស់ការចូលរួមវិនិយោគពីវិស័យឯកជនក្នុងគ្រប់ខ្សែច្រវាក់តម្លៃកសិកម្មតាមអភិក្រមភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍កសិកម្ម។

➢ **ការស្រាវជ្រាវនិងការអភិវឌ្ឍកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព**

- ពង្រឹង និងជំរុញការផ្ទេរបច្ចេកវិទ្យាតាមរយៈការផ្សព្វផ្សាយនិងការបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូ និងទីផ្សារដល់ប្រតិបត្តិករកៅស៊ូគ្រួសារ ដើម្បីបង្កើនការទទួលយកបច្ចេកវិទ្យាជឿនលឿនសមស្រប និងតម្លៃបន្ថែម
- ពង្រឹង និងជំរុញការស្រាវជ្រាវបច្ចេកវិទ្យាកៅស៊ូ និងក្លូនកៅស៊ូថ្មីធន់នឹងការប្រែប្រួលអាកាសធាតុសំដៅបង្កើនឧត្តមភាពប្រកួតប្រជែង
- ជំរុញការអភិវឌ្ឍជាចម្ការគំរូបង្ហាញ (Demonstration plantation) ដែលប្រើប្រាស់បច្ចេកទេសការ អនុវត្តកសិកម្មល្អ ដើម្បីបង្កើនការទទួលយករបស់កសិករកៅស៊ូគ្រួសារនូវបច្ចេកវិទ្យាសមស្រប
- ពង្រឹង និងចងក្រងសហគមន៍កសិកម្មកៅស៊ូគ្រួសារ ឲ្យទៅជាកន្លែងផលិតប្រមូលផ្តុំ ដើរដល់ទីផ្សារដើម្បីបង្កើនអំណាចចរចារតម្លៃជាមួយនឹងអ្នកទិញ ដែលនាំឲ្យទទួលបានចំណូលជាអតិបរមា។
- រៀបចំកសាងផែនការ និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ព័ត៌មានពាក់ព័ន្ធនឹងអនុវិស័យកៅស៊ូ និងពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ឲ្យមានប្រសិទ្ធភាព
- កៀរគររកប្រភពហិរញ្ញប្បទានសហប្រតិបត្តិការពីគ្រប់ដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រការស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូ ដូចជាការបន្តថែទាំ និងបង្កើតច្បារពូជគោលបន្ថែម ចម្ការពិសោធន៍បង្ហាញការអភិវឌ្ឍចម្ការកៅស៊ូគ្រួសារ និងបណ្តុះបណ្តាលធនធានមនុស្សរយៈពេលខ្លី និងវែង។

➢ **លើកកម្ពស់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម**

- ជំរុញការអនុវត្តយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា ពិសេសការភ្ជាប់ក្រុមផលិតករ សហគមន៍កសិកម្មជាមួយក្រុមអ្នកប្រមូលទិញ ឬក្រុមហ៊ុនឯកជនដែលប្រមូលទិញផលិតផលកសិកម្មសម្រាប់ការកែច្នៃ និងការនាំចេញ

- ជំរុញការរៀបចំ និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ដើម្បីគាំទ្រការអភិវឌ្ឍកសិ-ឧស្សាហកម្មឲ្យមានប្រសិទ្ធភាពខ្ពស់
- សម្របសម្រួលក្នុងការបង្កើតសួនកសិ-ឧស្សាហកម្មកែច្នៃ និងនាំចេញ ដែលគ្រប់គ្រង និងប្រតិបត្តិដោយផ្នែកឯកជន
- រៀបចំដំណើរការមន្ទីរពិសោធន៍ និងពង្រឹងសមត្ថភាពមន្ត្រីជំនាញសម្រាប់វិភាគគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម សហការជាមួយជំនាញពាក់ព័ន្ធតាមភារកិច្ច ឲ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា ដើម្បីជួយសម្រួលដល់ការអនុវត្តប្រព័ន្ធតាមដាននិងត្រួតពិនិត្យគុណភាពឲ្យកាន់តែមានប្រសិទ្ធភាព
- រៀបចំ និងអនុវត្តបទដ្ឋានគតិយុត្ត សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនានា ដើម្បីទប់ស្កាត់លើការប្រើប្រាស់សារធាតុគីមីដែលហាមឃាត់ ដោយត្រូវត្រួតពិនិត្យឲ្យបានតឹងរឹងបំផុត ដើម្បីធានាសុខុមាលភាពសាធារណៈ
- បង្កើនការសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលអំពីបច្ចេកទេសសម្រាប់ជំរុញការអភិវឌ្ឍកសិ-ឧស្សាហកម្ម។

➢ **ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កសិកម្មប្រកបដោយចីរភាព**

- ជំរុញគំនិតច្នៃប្រឌិតថ្មីៗសម្រាប់បង្កើនសន្ទុះទំនើបភាវូបនីយកម្មកសិកម្មឲ្យកាន់តែមានឧត្តមភាពប្រកួតប្រជែងខ្ពស់ ដោយយកចិត្តទុកដាក់លើការស្រាវជ្រាវ អភិវឌ្ឍន៍ ផ្សព្វផ្សាយ និងប្រើប្រាស់របកគំហើញថ្មីៗ ដូចជាប្រភេទពូជដំណាំថ្មីៗ បច្ចេកទេសផលិត កែច្នៃ បច្ចេកវិទ្យាកសិកម្មធន់នឹងការប្រែប្រួលអាកាសធាតុ ការប្រើប្រាស់ធាតុចូល កសិកម្មសមស្រប គ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្មច្នៃប្រឌិតថ្មីប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់
- បង្កើនការវិនិយោគលើការពង្រឹងសមត្ថភាពស្រាវជ្រាវកសិកម្មសម្រាប់ដំណាំអាទិភាព និងការអនុវត្តកម្មវិធីស្រាវជ្រាវសម្រាប់អភិវឌ្ឍន៍ តាមរយៈភាពជាដៃគូរវាងរដ្ឋាភិបាល វិស័យឯកជន និងអ្នកផលិត។

➢ **ការកសាងនិងអនុវត្តគម្រោងពាក់ព័ន្ធគោលនយោបាយអន្តរវិស័យ**

- រៀបចំកសាង អនុវត្ត តាមដាននិងវាយតម្លៃគម្រោង ផែនការសកម្មភាព ដែលមានចែងក្នុងឯកសារ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិផ្សេងទៀតទាក់ទងដល់ផ្នែកជំនាញ ពិសេសគម្រោងឬផែនការ សកម្មភាពក្នុងយុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់ និងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុ កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី ការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម គោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា។ល។

កម្មវិធីនេះត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន០៩ និងអនុវត្តដោយ (១)អគ្គនាយកដ្ឋានកសិកម្ម (២) អគ្គនាយកដ្ឋានកៅស៊ូ (៣)នាយកដ្ឋានកសិឧស្សាហកម្ម (៤)វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (៥)វិទ្យាស្ថានស្រាវជ្រាវដំណាំកៅស៊ូកម្ពុជា និង(៦)មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្ត។

## កម្មវិធីទី-២៖ ការលើកកម្ពស់ផលិតកម្មសត្វនិងសុខភាពសត្វ

<u>គោលបំណងកម្មវិធីទី-២៖</u> “ជំរុញផលិតកម្មសត្វក្នុងអត្រាកំណើន៣%ក្នុងមួយឆ្នាំ តាមរយៈការគ្រប់គ្រង និងការអភិវឌ្ឍការចិញ្ចឹមសត្វ កាត់បន្ថយហានិភ័យជំងឺឆ្លងសត្វ និងពង្រឹងការត្រួតពិនិត្យ អនាម័យសត្វនិងផលិតផលសត្វ”។

ដើម្បីសម្រេចនូវគោលដៅសូចនាករនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងជំរុញវិធានការគោលនយោបាយសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

➢ **ពង្រឹងផលិតកម្មសត្វ រួមទាំងលើកកម្ពស់ការគ្រប់គ្រង និងការបង្កាត់ពូជសត្វ**

- ជំរុញឲ្យការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មមានការកើនឡើង ទាំងក្នុងស្រទាប់ប្រជាកសិករ សហគមន៍ និងអ្នកចិញ្ចឹមសត្វផ្សេងទៀត

- អនុវត្តនិងផ្សព្វផ្សាយពីការអនុវត្តល្អលើការចិញ្ចឹមសត្វ (GAHP) ដល់អ្នកពាក់ព័ន្ធទាំងអស់ដែលចូលរួមនៅក្នុងផលិតកម្មសត្វ
- តាមដាននិងត្រួតពិនិត្យគុណភាពចំណីសត្វ ដើម្បីធានាប្រសិទ្ធភាពនៃការចិញ្ចឹមសត្វ
- កំណត់អត្តសញ្ញាណចុះបញ្ជី និងគ្រប់គ្រងទិន្នន័យសត្វ និងកសិដ្ឋានចិញ្ចឹមសត្វឲ្យបានល្អប្រសើរ
- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាថ្មីនៅក្នុងផលិតកម្មសត្វ និងការបង្កាត់ពូជសត្វតាមរយៈការបង្កើតកសិដ្ឋានបង្ហាញ និងការបណ្តុះបណ្តាលបច្ចេកទេសជំនាញ
- ជំរុញឲ្យប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការដាំដុះដំណាំចំណីសត្វ
- ជំរុញឲ្យមានការគ្រប់គ្រងកាកសំណល់សត្វនៅកសិដ្ឋាន សត្តឃាតដ្ឋាន និងរោងចក្រកែច្នៃសំខាន់ៗ។

➢ **ពង្រឹងសុខភាពសត្វ សុខភាពសាធារណៈបសុព្យាបាល និងសុខុមាលភាពសត្វ**
- ពង្រឹងការតាមដានជំងឺការចុះស្រាវជ្រាវនៅមូលដ្ឋាន ការធ្វើរោគវិនិច្ឆ័យក្នុងមន្ទីរពិសោធន៍ ការបង្ការ និងទប់ស្កាត់ជំងឺសត្វ និងជំងឺឆ្លងពីសត្វទៅមនុស្ស
- ប្រព័ន្ធព័ត៌មានសុខភាពសត្វត្រូវដំណើរការប្រកបដោយប្រសិទ្ធភាព
- ផ្តល់ការគាំទ្រ ទាំងផ្នែកបច្ចេកទេសនិងធនធានហិរញ្ញវត្ថុ ដល់ភ្នាក់ងារសុខភាពសត្វភូមិ (VAHWs) ដើម្បីចូលរួមក្នុងសកម្មភាពបង្កើនផលិតភាពសត្វនៅតាមមូលដ្ឋាន
- គ្រប់គ្រងសត្វនិងផលិតផលដើមកំណើតពីសត្វ រួមទាំងការត្រួតពិនិត្យដ៏មានប្រសិទ្ធភាពនៅតាមស្ថានីយចត្តាឡីស័ក និងកន្លែងប្រមូលផ្តុំសត្វ
- លើកកម្ពស់ការអនុវត្តជីវសុវត្ថិភាពនៅក្នុងខ្សែតម្លៃ។

➢ **លើកកម្ពស់ការផ្សព្វផ្សាយច្បាប់ ពង្រឹងការអនុវត្តច្បាប់ និងគោលនយោបាយនានា**
- រៀបចំពង្រឹងការអនុវត្ត និងបង្កើនការយល់ដឹងអំពីច្បាប់ស្តីពី សុខភាពសត្វនិងផលិតកម្មសត្វ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីពង្រឹងការគ្រប់គ្រងផ្នែកសុខភាពសត្វ និងផលិតកម្មសត្វឲ្យមាន ប្រសិទ្ធភាពខ្ពស់
- រៀបចំនីតិវិធីក្នុងការផ្តល់លិខិតអនុញ្ញាតដល់កសិដ្ឋាន សត្តឃាតដ្ឋាន កន្លែងកែច្នៃ មន្ទីរពិសោធន៍ ស្ថាប័នសិក្សាស្រាវជ្រាវ បសុឱសថ និងវ៉ាក់សាំងសត្វ សេវាបសុព្យាបាល និងកន្លែងលក់ផលិតផល ចំណីសត្វ
- រៀបចំនីតិវិធីក្នុងការផ្តល់វិញ្ញាបនបត្រដល់អ្នកផ្តល់សេវាបសុពេទ្យ និងផ្តល់ការគាំទ្រដល់ការបង្កើតគណៈបសុពេទ្យ (Veterinary Statutory Body - VSB)។

➢ **ជំរុញការងារស្រាវជ្រាវ និងអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ**
- អនុវត្ត និងគ្រប់គ្រងការងារស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ
- ពង្រឹងសមត្ថភាពស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ
- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍អភិរក្សសេនេទិចពូជសត្វ កែច្នៃទឹកមេជីវិតបង្កកគោ ការបង្កាត់ពូជសត្វដោយសិប្បនិម្មិត
- ពង្រឹងសមត្ថភាព និងប្រសិទ្ធភាពខ្ពស់ក្នុងការធ្វើរោគវិនិច្ឆ័យជំងឺសត្វ និងការអង្កេតតាមដានជំងឺសត្វ
- សិក្សាស្រាវជ្រាវគុណភាព និងសុវត្ថិភាព បសុឱសថ ចំណីសត្វ សាច់សត្វ និងផលិតផលសត្វ
- សិក្សាស្រាវជ្រាវភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ
- សិក្សាស្រាវជ្រាវ និងផលិតផលបសុឱសថនិងវ៉ាក់សាំង។

➢ **បង្កើនការអភិវឌ្ឍសមត្ថភាពស្ថាប័ននិងធនធានមនុស្សនៅក្នុងអនុវិស័យសុខភាពសត្វនិងផលិតកម្មសត្វ**
- ពង្រឹងសមត្ថភាពធនធានមនុស្សផ្នែកសុខភាពសត្វនិងផលិតកម្មសត្វ ខ្សែតម្លៃ និងការគ្រប់គ្រងកសិពាណិជ្ជកម្ម
- គាំទ្រដល់ការពង្រឹងការអប់រំក្នុងប្រព័ន្ធវេជ្ជសាស្ត្របសុព្យាបាល និងវិទ្យាសាស្ត្រសត្វ
- ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់មន្ត្រីសុខភាពសត្វនិងផលិតកម្មសត្វ មន្ត្រីនៃការិយាល័យផលិតកម្មនិងបសុព្យាបាលខេត្ត និងពេទ្យសត្វស្រុក។

- ➢ **លើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជនក្នុងផលិតកម្មសត្វ**
  - គាំទ្រដល់គំនិតផ្តួចផ្តើមរបស់វិស័យឯកជន នៅក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ
  - សម្របសម្រួលការពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការជាមួយនឹងវិស័យឯកជន អង្គការសង្គមស៊ីវិល និងសហគមន៍ចិញ្ចឹមសត្វ
  - ពង្រឹងការចែករំលែកព័ត៌មាន និងការសហការរវាងស្ថាប័នរដ្ឋាភិបាល និងវិស័យឯកជន។
- ➢ **ពង្រឹងសេវាផ្សព្វផ្សាយស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងអភិវឌ្ឍន៍ទីផ្សារ**
  - រៀបចំនិងបង្កើនការយល់ដឹង តាមរយៈឯកសារព័ត៌មាន អប់រំ និងប្រាស្រ័យទាក់ទង
  - បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលផ្សព្វផ្សាយថ្នាក់តំបន់ ដើម្បីជំរុញផលិតកម្មសត្វ និងលើកកម្ពស់ សុខភាពសត្វ
  - គាំទ្រព្រឹត្តិការណ៍រៀបចំឡើងដោយវិស័យសាធារណៈ និងវិស័យឯកជន ដែលផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយពាក់ព័ន្ធជាមួយនឹងសុខភាពសត្វ និងផលិតកម្មសត្វ។
- ➢ **ពង្រឹងកិច្ចសហប្រតិបត្តិការទាំងផ្នែកសេដ្ឋកិច្ច និងបច្ចេកទេសកម្រិតជាតិ និងអន្តរជាតិលើអនុវិស័យសុខភាពសត្វនិងផលិតកម្មសត្វ**
  - រៀបចំនិងចូលរួមនៅក្នុងសន្និសីទអំពីសុខភាពសត្វនិងផលិតកម្មសត្វ នៅថ្នាក់ជាតិ អាស៊ាន និងថ្នាក់អន្តរជាតិ
  - បង្កើតកិច្ចសហប្រតិបត្តិការភាពជាដៃគូខាងសេដ្ឋកិច្ច និងបច្ចេកទេសនៅថ្នាក់ជាតិ អាស៊ាន និងអន្តរជាតិ និងពង្រឹងទំនាក់ទំនងជាមួយនឹងដៃគូអភិវឌ្ឍន៍ អង្គការស្ថាប័នទ្វេភាគី និងពហុភាគី ជុំវិញបញ្ហានានា ដែលពាក់ព័ន្ធជាមួយនឹងសុខភាពសត្វ និងផលិតកម្មសត្វ។
  - រៀបចំកសាងនិងអនុវត្តគម្រោងផែនការសកម្មភាពទាំងអស់ ដែលមានគ្រោងក្នុងឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មជាតិផ្សេងទៀតទាក់ទងដល់ផ្នែកជំនាញ ពិសេសគម្រោងឬផែនការសកម្មភាពក្នុងយុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់ និងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុ ការបញ្ជ្រាបយេនឌ័រក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ។ល។

កម្មវិធីនេះ ត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន៤ និងអនុវត្តដោយអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត។

### កម្មវិធីទី-៣៖ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម

<u>គោលបំណងកម្មវិធីទី៣៖</u> "បង្កើនការគ្រប់គ្រងធនធានជលផលឲ្យមានប្រសិទ្ធភាពនិងនិរន្តរភាព ដោយពង្រឹង ការអនុវត្តច្បាប់ស្តីពីជលផល រក្សាការចាប់ផលនេសាទពីធម្មជាតិក្នុងរង្វង់៦០០ពាន់តោនក្នុងមួយឆ្នាំ បង្កើនផលវារីវប្បកម្ម២០%ក្នុងមួយឆ្នាំ និងធ្វើឲ្យសហគមន៍នេសាទមានកម្រិតជីវភាពកាន់តែប្រសើរឡើង"។

ដើម្បីសម្រេចនូវគោលដៅសូចនាករនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងជំរុញវិធានការគោលនយោបាយសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

(១) ពង្រឹងការសិក្សាស្រាវជ្រាវ ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផលប្រកបដោយចីរភាព ស្របតាមការអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១៥-២០២៤ និងសេចក្តីថ្លែងការណ៍ស្តីពីគោលនយោបាយវិស័យជលផលជាតិ ពិសេសតាមរយៈការពង្រឹងការអនុវត្តច្បាប់ និងការប្រយុទ្ធប្រឆាំងនឹងបទល្មើសនេសាទគ្រប់ប្រភេទជាអាទិ៍៖ ការពង្រឹងការគ្រប់គ្រងឧបករណ៍នេសាទ ការលុបបំបាត់ការនេសាទហួសកម្រិត ការពង្រឹងសមត្ថភាពសហគមន៍នេសាទ ក្នុងការគ្រប់គ្រង ប្រើប្រាស់ និងអភិរក្សធនធានជលផល ការអភិរក្ស ការការពារជីវចម្រុះ និងជម្រកវារីសត្វ ការថែទាំនិងជំរុញការដាំព្រៃលិចទឹក និងព្រៃកោងកាង ការកំណត់ ព្រំប្រទល់ព្រៃលិចទឹក និងកន្លែងអភិរក្សជលផល ព្រមទាំងកសាងសមត្ថភាពអង្គភាព ការអភិវឌ្ឍធនធានមនុស្ស ការសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយ។

(២) ការបង្កើនការអភិវឌ្ឍវារីវប្បកម្ម ដោយផ្តល់ការគាំទ្រដល់កសិដ្ឋានចិញ្ចឹមត្រី ដូចជាបច្ចេកទេស បង្កាត់ពូជត្រីមានគុណភាព ឥណទាន ទីផ្សារ ការសិក្សាស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយវារីវប្បកម្ម ស្របតាមផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍វារីវប្បកម្មឆ្នាំ២០១៦-២០៣០។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបន្តពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍធនធានជលផលប្រកបដោយចីរភាព ព្រមទាំងកែលម្អគុណភាព និងសុវត្ថិភាពផល ផលិតផលជលផល និងបង្កើនផលវារីវប្បកម្មពី២៥៨៣ាន់តោននាឆ្នាំ២០១៩ ឲ្យកើនដល់៦១៩៣ាន់តោននៅឆ្នាំ២០២៣ ដោយបង្កើនការគាំទ្រដល់កសិដ្ឋានចិញ្ចឹមត្រី ក្នុងន័យបង្កើនការគាំទ្រដល់ការការពារធនធានជលផល។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់យុទ្ធសាស្ត្រសំខាន់សម្រាប់ការអនុវត្តកម្មវិធីទី៣នេះ រួមមាន៖

➢ **ពង្រឹងការគ្រប់គ្រង និងអភិរក្សធនធានជលផល**

- ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍន៍សហគមន៍នេសាទ៖ បន្តពង្រឹងសហគមន៍នេសាទឲ្យក្លាយជា សហគមន៍មានភាពម្ចាស់ការ ដំណើរការល្អ រឹងមាំ និងសកម្មក្នុងការគ្រប់គ្រង និងអភិរក្សធនធានជលផលឲ្យមាននិរន្តរភាព ពិសេសជំរុញនិងគាំទ្រផ្តល់ឱកាសឲ្យសហគមន៍នេសាទអាចរកប្រាក់ចំណូលសម្រាប់ ដំណើរការសហគមន៍ និងអភិរក្សធនធានជលផលប្រកបដោយប្រសិទ្ធភាព ដោយសហការជាមួយរដ្ឋបាល ពាក់ព័ន្ធថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដើម្បីប្រែក្លាយជា "សហគមន៍នេសាទគ្មានបទល្មើសជលផល"
- ការគ្រប់គ្រងដែននេសាទ៖ បង្កើនកិច្ចសហការជាមួយអាជ្ញាធរដែនដីគ្រប់ថ្នាក់ ចុះទប់ស្កាត់ការទន្ទ្រានឈូសឆាយបំផ្លិចបំផ្លាញយកដីព្រៃលិចទឹកនិងព្រៃកោងកាងនៅតាមមូលដ្ឋាន ជាពិសេសយកចិត្តទុកដាក់និងទប់ស្កាត់រាល់ឧបករណ៍នេសាទដែលបំផ្លិចបំផ្លាញធ្ងន់ធ្ងរដល់ធនធានធម្មជាតិនិងកែលម្អដែននេសាទ។ រៀបចំផែនទីកំណត់ព្រំប្រទល់ដែននេសាទ តំបន់អនុញ្ញាតឲ្យដាំដុះវារីរុក្ខជាតិ តំបន់នេសាទ និងការចេញលិខិតអនុញ្ញាតឲ្យធ្វើអាជីវកម្មនេសាទ និងការប្រើប្រាស់ទូក កាណូតនាវានេសាទ ព្រមទាំងតាមដាន និងវាយតម្លៃសភាពការណ៍អាជីវកម្មនេសាទ និងទប់ស្កាត់រាល់សកម្មភាពបទល្មើសជលផលគ្មានរបាយការណ៍និងគ្មានការអនុញ្ញាត។

➢ **ការពារនិងអភិរក្សធនធានជលផល៖**

- ត្រូវបន្តគ្រប់គ្រងកន្លែងអភិរក្សធនធានជលផលទាំងអស់ ទាំងក្នុងដែននេសាទសាធារណៈ និងក្នុងកន្លែងនេសាទសហគមន៍នេសាទឲ្យខាងតែបានព្រោះដែនអភិរក្សទាំងនេះជាជម្រកត្រីមេពូជដ៏សំខាន់ សម្រាប់ថែរក្សាត្រីមេពូជឲ្យបានគង់វង្ស និងធានានិរន្តរភាពផលនេសាទ ដែលមានសារៈសំខាន់ដល់និរន្តរភាពនៃធនធានជលផល។

➢ **អភិវឌ្ឍន៍វារីវប្បកម្មទឹកសាបនិងសមុទ្រ**

- ជំរុញការអភិវឌ្ឍវារីវប្បកម្មក្នុងកំណើន២០%/ឆ្នាំ ដើម្បីបំពេញកំណើនតម្រូវការសាច់ត្រីជាអាហារ និងកាត់បន្ថយការនេសាទហួសកម្រិតនោះ៖ ការអភិវឌ្ឍវារីវប្បកម្មត្រូវតែជំរុញឲ្យបានខ្លាំងក្លា ទាំងខ្នាតតូច មធ្យម និងធំ ដោយធានាឲ្យបានទាំងកំណើនបរិមាណ និងទាំងគុណភាព សុវត្ថិភាពចំណីអាហារ ដោយត្រូវជំរុញការអនុវត្ត **ផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍វារីវប្បកម្មឆ្នាំ២០១៦-២០៣០។** ពិសេស វិធានការពង្រឹងសមត្ថភាពក្នុងការផលិតនូវកូនត្រីពូជក្នុងស្រុក សម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ដើម្បី ឆ្លើយតបនឹងតាមតម្រូវការរបស់អ្នកចិញ្ចឹម ជាពិសេសប្រភេទត្រីមានតម្លៃសេដ្ឋកិច្ចខ្ពស់ ព្រមទាំងបន្តផ្តល់នូវបច្ចេកទេសថ្មីៗ និងបច្ចេកទេសសម្រាប់ជម្រុញការបង្កាត់ពូជត្រី និងទីកន្លែងបង្កាត់ភ្ញាស់ពូជត្រី និងអនុវត្តគោលការណ៍អនុវត្តវារីវប្បកម្មល្អ។
- ជំរុញលើកទឹកចិត្តដល់វិស័យឯកជនទាំងក្នុងនិងក្រៅប្រទេស ឲ្យធ្វើការវិនិយោគលើការអភិវឌ្ឍវារីវប្បកម្ម ពិសេសការចិញ្ចឹមត្រី និងបង្កង រួមទាំងការកែច្នៃផលិតផលជលផលប្រកបដោយគុណភាព និងសុវត្ថិភាព

- កំណត់ឲ្យបានជាក់លាក់ពីតំបន់ដែលមានសក្ដានុពល សម្រាប់វិនិយោគវារីវប្បកម្មពីសំណាក់អ្នកវិនិយោគ ក្នុង និងក្រៅប្រទេស ជាពិសេសចំពោះការចិញ្ចឹមត្រីឆ្តោរនិងត្រីរ៉ស់ ត្រូវផ្ដល់បច្ចេកទេសបង្កាត់ពូជត្រីនិងផ្ដល់នូវបច្ចេកទេសគ្រប់គ្រង និងតាមដានឲ្យមានប្រសិទ្ធភាព ដើម្បីចៀសវាងការប្រើចំណីដែល បានមកពីការប្រើឧបករណ៍នេសាទខុសច្បាប់ដូចជាស្បៃមុងចាប់កូនត្រីធ្វើជាចំណីជាដើម
- បង្កើតសមាគមន៍វារីវប្បកម្ម និងជំរុញឲ្យមានការធ្វើផលិតកម្មតាមកិច្ចសន្យា ជាមួយអ្នកប្រមូលទិញ ឬក្រុមហ៊ុនប្រមូលទិញសម្រាប់នាំចេញ
- បន្តជំរុញការងារស្រាវជ្រាវ ការអប់រំ និងអភិវឌ្ឍន៍បច្ចេកទេសវារីវប្បកម្ម និងបង្កើនការផ្សព្វផ្សាយបច្ចេកទេសបង្កាត់កូនត្រីពូជនិងចិញ្ចឹមដល់កសិករ ប្រជានេសាទ និងសហគមន៍នេសាទ។

➢ **ការគ្រប់គ្រង និងអភិវឌ្ឍន៍ខ្សែច្រវ៉ាក់តម្លៃជលផល**

- អភិវឌ្ឍបច្ចេកវិទ្យាកែច្នៃ និងលើកកម្ពស់អាហារូបត្ថម្ភ រៀបចំនិងសាកល្បងគោលការណ៍ណែនាំបច្ចេកទេសកែច្នៃតាមស្តង់ដារ និងជំរុញការអនុវត្តបច្ចេកទេសកែច្នៃប្រសើរឡើង ដើម្បីបង្កើនតម្លៃបន្ថែម
- ពង្រឹងការត្រួតពិនិត្យ និងវិភាគគុណភាពផល ផលិតផលជលផល ដើម្បីការពារសុខភាពសាធារណៈ និងជំរុញការនាំចេញ
- លើកកម្ពស់ការផលិតឆ្លើយតបតាមស្តង់ដារគុណភាព និងជំរុញទីផ្សារក្នុងស្រុកនិងក្រៅស្រុក ជាពិសេសតាមរយៈការពង្រឹងសមត្ថភាពប្រព័ន្ធគ្រប់គ្រងគុណភាព និងសុវត្ថិភាព ដោយផ្ដល់ការបណ្ដុះបណ្ដាល និងផ្សព្វផ្សាយគោលការណ៍ណែនាំបច្ចេកទេសផ្សេងៗដែលពាក់ព័ន្ធ ។

➢ **ការស្រាវជ្រាវ និងអភិវឌ្ឍន៍ធនធានជលផល**

- ស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកទេសធនធានជលផលទឹកសាបនិងសមុទ្រ
- បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ និងផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវធនធានជលផលទឹកសាបនិងសមុទ្រ
- ជម្រុញ និងពង្រឹងកិច្ចសហការសិក្សាស្រាវជ្រាវធនធានជលផលទឹកសាបនិងសមុទ្រ ជាមួយវិទ្យាស្ថានស្រាវជាវ សាកលវិទ្យាល័យ នៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ និងស្ថាប័នពាក់ព័ន្ធដ៏ទៃទៀត
- ពង្រឹងសមត្ថភាពមន្ត្រីស្រាវជ្រាវដែលធ្វើការងារស្រាវជ្រាវវិទ្យាស្ត្រជលផលទឹកសាប និងសមុទ្រ

➢ **ពង្រឹងសមត្ថភាពមន្ត្រីជលផល ការអនុវត្តច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យជលផល**

- អនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យជលផល និងបន្តពិនិត្យកែសម្រួលច្បាប់ លិខិតបទដ្ឋាននានាពាក់ព័ន្ធវិស័យជលផលឲ្យទាន់សភាពការណ៍ជាក់ស្តែង
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរដែនដីគ្រប់ថ្នាក់ ដើម្បីបង្ក្រាបបទល្មើសជលផលនៅក្នុង មូលដ្ឋាន ជាពិសេសយកចិត្តទុកដាក់ទប់ស្កាត់រាល់ឧបករណ៍នេសាទ ដែលបំផ្លិចបំផ្លាញធ្ងន់ធ្ងរដល់ធនធានធម្មជាតិ និងទប់ស្កាត់នូវរាល់សកម្មភាពបទល្មើសជលផល ការទន្ទ្រានយកដីព្រៃលិចទឹក ព្រៃកោងកាង និងដីដែលស្ថិតនៅក្នុងកន្លែងនេសាទសហគមន៍។
- អនុវត្តផែនការសកម្មភាពជាតិស្តីពីការប្រយុទ្ធប្រឆាំង និងទប់ស្កាត់បទល្មើសនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត( NPOA IUU ) Fishing-National Plan of Action Illegal Fishing Unreported and Unregulated ) និងផែនការជាតិត្រួតពិនិត្យមោងអធិការកិច្ចសមុទ្រ ( NPCI-National Plan for Control and Inspection ) និងផែនការជាតិសម្រាប់ការគ្រប់គ្រងនិងអធិការកិច្ចឲ្យស្របទៅតាមច្បាប់ជាតិ និងសន្ធិសញ្ញាអន្តរជាតិ
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិនានា ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍនិងគ្រប់គ្រងវិស័យជលផលនៅកម្ពុជាឲ្យបានខ្លាំងក្លាថែមទៀត សំដៅធានានិរន្តភាពធនធានជលផល កាត់បន្ថយ

ភាពក្រីក្រ ធានាសន្តិសុខ និងសុវត្ថិភាពស្បៀង ព្រមទាំងចូលរួមសម្រេចឲ្យបាន "គោលដៅ អភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០"

- រៀបចំកសាង និងអនុវត្តផែនការសកម្មភាពដែលមានគ្រោងក្នុងឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិផ្សេងទៀតទាក់ទងនឹងជលផល ពិសេសគម្រោងឬផែនការសកម្មភាពក្នុងយុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់ និងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុ ការបញ្ជ្រាបយេនឌ័រក្នុងអនុវិស័យជលផល និងក្នុងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា។ល។
- អភិវឌ្ឍធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលបច្ចេកទេសជំនាញ និងបទដ្ឋានគតិយុត្តិដល់មន្ត្រីជលផលនិងអ្នកពាក់ព័ន្ធ

កម្មវិធីនេះ ត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន៥ និងអនុវត្តដោយរដ្ឋបាលជលផល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្ត។

## កម្មវិធីទី-៤៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ

<u>គោលបំណងកម្មវិធីទី៤៖</u> "បង្កើនការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយចីរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ជំរុញការដាំដុះព្រៃឈើឡើងវិញ បង្កើនការស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើនិងសត្វព្រៃ ព្រមទាំងពង្រឹងសមត្ថភាពសហគមន៍ព្រៃឈើឲ្យមានជីវភាពកាន់តែប្រសើរឡើង"។

➢ **គ្រប់គ្រង និងអភិវឌ្ឍន៍ព្រៃឈើ**
- អភិវឌ្ឍន៍សហគមន៍ព្រៃឈើ និងគ្រប់គ្រងផល អនុផលព្រៃឈើ ពិសេសត្រូវបន្តពង្រឹងនិងពង្រីក សហគមន៍ព្រៃឈើ ដោយជួយប្រជាសហគមន៍ជនបទឲ្យបង្កើនចំណូល លើកកម្ពស់ជីវភាពរស់នៅ តាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម និងចិញ្ចឹមសត្វ
- អភិវឌ្ឍន៍ចម្ការឈើដាំ និងការងាររុក្ខវប្បកម្ម ក្នុងគោលដៅពង្រីកគម្របព្រៃឈើ ដោយត្រូវបន្តជំរុញការស្តារដាំដុះព្រៃឈើឡើងវិញនៅលើដីព្រៃរេចរិល ដីព្រៃរងការធ្វើអាជីវកម្ម ដីទំនេររបស់រដ្ឋ និងដីព្រៃដែលបានដកហូតពីសម្បទានដីសេដ្ឋកិច្ច ដោយសហការជាមួយផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយ សម្រាប់ចែកចាយជូនប្រជាពលរដ្ឋដាំដុះ
- គ្រប់គ្រង និងអភិវឌ្ឍន៍ឧស្សាហកម្មព្រៃឈើ ពាណិជ្ជកម្ម និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការអភិវឌ្ឍវិស័យព្រៃឈើ។

➢ **ពង្រឹងការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើនិងសត្វព្រៃ**
- ពង្រឹងការស្រាវជ្រាវ ថែរក្សា និងអភិវឌ្ឍសត្វព្រៃ និងជីវចម្រុះ
- សិក្សាស្រាវជ្រាវការស្តារព្រៃឈើរេចរឹល ជំរុញការអនុវត្តកសិ-រុក្ខកម្មទប់ស្កាត់ការហូរច្រោះដី និងពង្រឹងសមត្ថភាព ក្នុងការគ្រប់គ្រងតំបន់ស្តារ និងអភិវឌ្ឍន៍ព្រៃឈើ សំដៅចូលរួមចំណែកដោះស្រាយ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ
- រៀបចំបង្កើតសួនរុក្ខសាស្ត្រ (Botanical Garden) នៅតាមតំបន់អេកូឡូស៊ីរុក្ខជាតិ ក្នុងគោលបំណងអប់រំបណ្តុះបណ្តាល និងផ្សព្វផ្សាយនូវប្រភេទរុក្ខជាតិមានដោយកម្រ និងជិតផុតពូជ ព្រមទាំងដាក់តាំងបង្ហាញនូវសំណាកប្រភេទរុក្ខជាតិសំខាន់ៗ ប្រភេទ គ្រួសារ និងអំបូរដទៃទៀត

➢ **គ្រប់គ្រងឧទ្យានសួនសត្វនិងសង្គ្រោះថែរក្សាសត្វព្រៃ**
- ការសង្គ្រោះ ថែរក្សាសត្វព្រៃ និងអប់រំផ្សព្វផ្សាយ ដើម្បីចូលរួមចំណែកទប់ស្កាត់ការផុតពូជធនធានសត្វព្រៃ និងជីវចម្រុះ
- សម្របសម្រួលបង្កើតសេវាកម្មទេសចរណ៍ ដើម្បីបង្កើនប្រាក់ចំណូលដល់សហគមន៍ព្រៃឈើមូលដ្ឋាន

- **ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ**
  - ផ្សព្វផ្សាយនិងអនុវត្តច្បាប់ស្តីពីព្រៃឈើ ចុះទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើឲ្យមានប្រសិទ្ធភាព ដោយសហការជាមួយគណៈបញ្ជាការឯកភាពរាជធានី ខេត្ត
  - ចុះត្រួតពិនិត្យតំបន់សម្បទានដីសេដ្ឋកិច្ច ដើម្បីធានាថាដំណើរការដីសម្បទានសេដ្ឋកិច្ចទាំងនោះប្រព្រឹត្តទៅប្រកបដោយចីរភាព និងប្រសិទ្ធភាពខ្ពស់។
- **ពង្រឹងការគ្រប់គ្រង និងសេវាគាំទ្រអង្គភាព**
  - សម្របសម្រួលរៀបចំធ្វើបច្ចុប្បន្នភាពកម្មវិធីព្រៃឈើជាតិ ឆ្លើយតបនឹងស្ថានភាពក្នុងបរិបទកំណែទម្រង់បច្ចុប្បន្ន សំដៅធានាបានស្ថិរភាពរឹងមាំលើការអភិវឌ្ឍវិស័យព្រៃឈើជាតិ
  - រៀបចំកសាងនិងអនុវត្តគម្រោងផែនការសកម្មភាពទាំងអស់ ដែលមានគ្រោងក្នុងឯកសារ យុទ្ធសាស្ត្រ និងផែនការសកម្មផ្សេងទៀតដែលទាក់ទងដល់ផ្នែកជំនាញ ពិសេសគម្រោងឬផែនការសកម្មភាពក្នុងយុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់ និងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុ កម្មវិធីសកម្មភាពជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី ការបញ្ជ្រាបយេនឌ័រក្នុងអនុវិស័យ ព្រៃឈើ។

កម្មវិធីនេះ ត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន៤ និងអនុវត្តដោយរដ្ឋបាលព្រៃឈើ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្ត។

## កម្មវិធីទី-៥៖ ការបង្កើនប្រសិទ្ធភាព សេវាគាំទ្រ និងការអភិវឌ្ឍធនធានមនុស្ស

<u>គោលបំណងកម្មវិធីទី៥៖</u> "បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រ និងពង្រឹងសមត្ថភាពផ្នែកអប់រំនិងបណ្តុះបណ្តាល សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព"។

- **ការពង្រឹងស្ថាប័ន៖** ជំរុញការគ្រប់គ្រងអង្គភាពជំនាញក្រោមឱវាទក្រសួង ឲ្យមានសមត្ថភាព គ្រប់គ្រាន់ក្នុងការអនុវត្តគោលនយោបាយ សម្រាប់អភិវឌ្ឍវិស័យកសិកម្មប្រកបដោយចីរភាព។
- **ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ៖** បង្កើនសមត្ថភាពកសាង និងអនុវត្តផែនការយុទ្ធសាស្ត្រ ពង្រឹងប្រព័ន្ធព័ត៌មាន និងទីផ្សារកសិកម្ម ការគ្រប់គ្រងគម្រោងវិនិយោគ សាធារណៈនិងឯកជន ធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាព ភាពស័ក្តិសិទ្ធក្នុងការអនុវត្តថវិកាកម្មវិធីពេញលេញ ការធ្វើអធិការកិច្ច សវនកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ និងសេវាគាំទ្រពាក់ព័ន្ធផ្សេងទៀតប្រកបដោយប្រសិទ្ធភាព។
- **ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកសិកម្ម៖** បង្កើនចំណេះដឹងផ្នែកបច្ចេកទេស និងជំនាញកសិកម្មពាក់ព័ន្ធនានា ស្រាវជ្រាវបន្ថែមនូវបច្ចេកវិទ្យានិងរបកគំហើញថ្មីៗ សំដៅពង្រឹងនិងពង្រីកធនធានមនុស្សក្នុងវិស័យកសិកម្ម ដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារ ការងារ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

កម្មវិធីនេះ ត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន១៣ និងអនុវត្តដោយ(១)នាយកដ្ឋានផែនការនិងស្ថិតិ (២)នាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ (៣)នាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស (៤)នាយកដ្ឋានសវនកម្មផ្ទៃក្នុង (៥)នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (៦)នាយកដ្ឋាននីតិកម្មកសិកម្ម (៧) នាយកដ្ឋានកិច្ចការរដ្ឋបាល (៨) មជ្ឈមណ្ឌលឯកសារនិងព័ត៌មានកសិកម្ម (៩)អគ្គាធិការដ្ឋាន (១០)សាកលវិទ្យាល័យភូមិន្ទកសិកម្ម (១១) សាលាជាតិកសិកម្មព្រែកលៀប (១២)សាលាជាតិកសិកម្មកំពង់ចាម និង (១៣)មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្ត។

កម្មវិធីទាំង៥របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានគាំទ្រដោយអនុកម្មវិធីសរុបចំនួន៤១ ក្នុងនោះអង្គភាពថ្នាក់កណ្តាលមានអនុកម្មវិធីចំនួន៣៦ និងមន្ទីរកសិកម្មរាជធានី ខេត្ត មានអនុកម្មវិធីចំនួន៥។

តារាង ១: (ក).កម្មវិធី អ្នកគ្រប់គ្រង និងអង្គភាពទទួលខុសត្រូវ

| គោលបំណងគោលនយោបាយ | កម្មវិធី | អ្នកគ្រប់គ្រង | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|
| "ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ ព្រមទាំងបង្កើន ប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព" | កម្មវិធីទី-១៖<br>ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច | លោកជំទាវ<br>ចាន់ ផលឿន | អគ្គនាយកដ្ឋានកសិកម្ម<br>អគ្គនាយកដ្ឋានកៅស៊ូ<br>នាយកដ្ឋានកសិឧស្សា.<br>វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា<br>វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា |
| | កម្មវិធីទី-២៖<br>ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ | ឯកឧត្តម តាន់ ផាន់ណារ៉ា | អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ |
| | កម្មវិធីទី-៣៖<br>ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម | ឯកឧត្តម អេង ជាសាន | រដ្ឋបាលជលផល |
| | កម្មវិធីទី-៤៖<br>ការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ | ឯកឧត្តម កែវ អូម៉ាលីស្ស | រដ្ឋបាលព្រៃឈើ |
| | កម្មវិធីទី-៥៖<br>ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងការអភិវឌ្ឍធនធានមនុស្ស | ឯកឧត្តម ស្រី វុឌ្ឍី | ១៣ អង្គភាព |

**តារាង ១: (ខ). អនុកម្មវិធី អ្នកគ្រប់គ្រង និងអង្គភាពទទួលខុសត្រូវ**

| គោលបំណងគោលនយោបាយ | អនុកម្មវិធី | អ្នកគ្រប់គ្រងផ្ទាល់ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|
| គោលបំណង គ.ប ទី១<br>*"បង្កើនផលិតភាព ពិពិធកម្មកសិកម្ម ការប្រកួតប្រជែង និងពាណិជ្ជូបនីយកម្មកសិកម្ម"*<br><br>កម្មវិធីទី-១៖ ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច | អនុកម្មវិធីទី-១.១៖<br>ការអភិវឌ្ឍដំណាំស្រូវ | ឯកឧត្តម ងិន ឆាយ | អគ្គនាយកដ្ឋានកសិកម្ម |
| | អនុកម្មវិធីទី-១.២៖<br>ការអភិវឌ្ឍដំណាំសាកវប្បកម្ម | ឯកឧត្តម ងិន ឆាយ | |
| | អនុកម្មវិធីទី-១.៣៖<br>ការអភិវឌ្ឍដំណាំឧស្សាហកម្ម | ឯកឧត្តម ងិន ឆាយ | |
| | អនុកម្មវិធីទី-១.៤៖<br>ការពង្រឹងសមត្ថភាពអង្គភាព និងផ្តល់សេវាគាំទ្រ (GDA) | ឯកឧត្តម ងិន ឆាយ | |
| | អនុកម្មវិធីទី-១.៥៖<br>ការអភិវឌ្ឍកៅស៊ូធម្មជាតិ | ឯកឧត្តម ប៉ុល សុជា | អគ្គនាយកដ្ឋានកៅស៊ូ |
| | អនុកម្មវិធីទី-១.៦៖<br>ការលើកកម្ពស់គុណភាពការងារពិសោធន៍ និងស្រាវជ្រាវកៅស៊ូ | លោក ម៉ក់ សុភាវិស្នា | វិទ្យាស្ថានស្រាវជ្រាវ កៅស៊ូកម្ពុជា (IRCC) |
| | អនុកម្មវិធីទី-១.៧ ៖<br>ការលើកកម្ពស់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម | លោក គង់ ភាជ | នាយកដ្ឋានកសិ-ឧស្សាហកម្ម |
| | អនុកម្មវិធីទី-១.៨៖<br>ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កសិកម្មប្រកបដោយចីរភាព | បណ្ឌិត អ៊ុក ម៉ាការា | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (កាឌី) |
| | អនុកម្មវិធីទី-១.៩៖<br>ការបង្កើនផលិតភាពកសិកម្ម រាជធានី ខេត្ត | | ២៥ អង្គភាពថវិកា (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) |

| | | | |
|---|---|---|---|
| <u>គោលបំណង គ.ប ទី១</u><br>*“បង្កើនផលិតភាព ពិពិធកម្មកសិកម្ម ការប្រកួតប្រជែង និងពាណិជ្ជូបនីយកម្មកសិកម្ម”*<br><br><u>កម្មវិធីទី-២៖</u><br>*ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ* | អនុកម្មវិធីទី-២.១៖<br>ការជំរុញផលិតកម្មសត្វ | លោកបណ្ឌិត សួន សុធឿន<br>លោកបណ្ឌិត ស៊ិន សាន | អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ |
| | អនុកម្មវិធីទី-២.២៖<br>ការលើកកម្ពស់សុខភាពសត្វ | លោក ហ៊ិល ដាវុន<br>លោកស្រី ហេង ម៉ូរ៉ានី<br>លោកបណ្ឌិត ស៊ិន សាន | |
| | អនុកម្មវិធីទី-២.៣៖<br>ការពង្រឹងសមត្ថភាព និងសេវាគាំទ្រអង្គភាព | លោក នូ យុត្តិកា<br>លោក គឹម សាវឿន | |
| | អនុកម្មវិធីទី-២.៤៖<br>ការជំរុញផលិតកម្មសត្វ និងសុខភាពសត្វ រាជធានីខេត្ត | | ២៥ អង្គភាពថវិកា (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) |
| <u>គោលបំណង គ.ប ទី២</u><br>*“បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព”*<br><u>កម្មវិធីទី-៣៖</u><br>ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម | អនុកម្មវិធីទី-៣.១៖<br>ការគ្រប់គ្រង និងការអភិរក្សធនធានជលផល | លោក អ៊ុក វិបុល | រដ្ឋបាលជលផល |
| | អនុកម្មវិធីទី-៣.២៖<br>ការអភិវឌ្ឍវារីវប្បកម្ម និងខ្សែច្រវាក់តម្លៃជលផល | លោក ថាយ សុមុន្នី | |
| | អនុកម្មវិធីទី-៣.៣៖<br>ការពង្រឹងសមត្ថភាព និងសេវាគាំទ្រអង្គភាព | លោក ធ សែនសិរីវឌ្ឍន៍ | |
| | អនុកម្មវិធីទី-៣.៤៖<br>ការពង្រឹងការគ្រប់គ្រងធនធានជលផល រាជធានី ខេត្ត | | ២៥ អង្គភាពថវិកា (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) |
| <u>គោលបំណង គ.ប ទី២</u><br>*“បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព”* | អនុកម្មវិធីទី-៤.១៖<br>ការគ្រប់គ្រងព្រៃឈើ | លោកបណ្ឌិត យន សារ៉េត | រដ្ឋបាលព្រៃឈើ |
| | អនុកម្មវិធីទី-៤.២៖<br>ការស្រាវជ្រាវ និងការអភិវឌ្ឍព្រៃឈើនិងសត្វព្រៃ | លោក ចាន់ សុវត្ថិភាព | |

| | | | |
|---|---|---|---|
| **<u>កម្មវិធីទី-៤៖</u>**<br>ការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ | អនុកម្មវិធីទី-៤.៣៖<br>ការពង្រឹងការគ្រប់គ្រង និងសេវាគាំទ្រ | លោក សៀ វ៉ា | |
| | អនុកម្មវិធីទី-៤.៤៖<br>ការពង្រឹងការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃ រាជធានី ខេត្ត | | ២៥ អង្គភាពថវិកា (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) |
| <u>គោលបំណង គ.ប ទី១</u><br>*"បង្កើនផលិតភាព ពិពិធកម្មកសិកម្ម ការប្រកួតប្រជែង និងពាណិជ្ជូបនីយកម្មកសិកម្ម"*<br><br><u>គោលបំណង គ.ប ទី២</u><br>*"បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព"*<br><br>**<u>កម្មវិធីទី-៥៖</u>**<br>ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងការអភិវឌ្ឍធនធានមនុស្ស | អនុកម្មវិធីទី-៥.១៖<br>ការលើកកម្ពស់ការកសាងនិងការអនុវត្តផែនការគោលនយោបាយ និងវិនិយោគកសិកម្ម | លោក ម៉ក់ ម៉ូនី | ន.ផែនការ និងស្ថិតិ |
| | អនុកម្មវិធីទី-៥.២៖<br>ការបង្កើនប្រសិទ្ធភាពការរៀបចំ គ្រប់គ្រង និងការអនុវត្តថវិកា | លោកស្រី គង់ សុធីរ | ន.គណនេយ្យ ហិរញ្ញវត្ថុ |
| | អនុកម្មវិធីទី-៥.៣៖<br>ការគ្រប់គ្រងស្ថាប័ននិងការអភិវឌ្ឍធនធានមនុស្ស | លោក ទី ចាន់ណា | ន.បុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស |
| | អនុកម្មវិធីទី-៥.៤៖<br>ការបង្កើនប្រសិទ្ធភាពការងារសវនកម្មផ្ទៃក្នុង | លោកស្រី ងិន សុនាថ | ន.សវនកម្មផ្ទៃក្នុង |
| | អនុកម្មវិធីទី-៥.៥៖<br>ការលើកកម្ពស់សមត្ថភាព និងប្រសិទ្ធភាពការងារសហប្រតិបត្តិការអន្តរជាតិ | លោក ព្រំ សុម៉ានី | ន.សហប្រតិបត្តិការអន្តរជាតិ |
| | អនុកម្មវិធីទី-៥.៦៖<br>ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ពាក់ព័ន្ធការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម | លោក ភុំ រ៉ា | ន.នីតិកម្មកសិកម្ម |
| | អនុកម្មវិធីទី-៥.៧៖<br>ការពង្រឹងការងាររដ្ឋបាលនិងការបញ្ជ្រាបយេនឌ័រ | លោក ជា ច័ន្ទវ៉ាសនា | ន.កិច្ចការរដ្ឋបាល |

| | | | |
|---|---|---|---|
| | អនុកម្មវិធីទី-៥.៨៖<br>ការបង្កើនប្រសិទ្ធភាពការងារអធិការកិច្ច | ឯ.ឧ គង់ វ៉ាញ | អគ្គាធិការដ្ឋាន |
| | អនុកម្មវិធីទី-៥.៩៖<br>ការគ្រប់គ្រងឯកសារ និងប្រព័ន្ធព័ត៌មានកសិកម្ម (AIDOC) | លោក ហុង ណារិត | AIDOC |
| | អនុកម្មវិធីទី-៥.១០៖<br>ការពង្រឹងគុណភាពអប់រំ និងបណ្តុះបណ្តាលធនធានមនុស្សលើបច្ចេកទេសកសិកម្មនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម | ឯ.ឧ ង៉ោ ប៊ុនថាន | សាកលវិទ្យាល័យ ភូមិន្ទកសិកម្ម |
| | អនុកម្មវិធីទី-៥.១១៖<br>លារលើកកម្ពស់គុណភាពអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្មនៅសាលាជាតិកសិកម្មព្រែកលៀប | លោក ធន់ វឌ្ឍនា | សាលាជាតិកសិកម្មព្រែកលៀប |
| | អនុកម្មវិធីទី-៥.១២៖<br>ការពង្រឹងគុណភាពប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលធនធានមនុស្សវិស័យកសិកម្មរបស់សាលាជាតិកសិកម្មកំពង់ចាម | លោក សួន សេរី | សាលាជាតិ<br>កសិកម្មកំពង់ចាម |
| | អនុកម្មវិធីទី-៥.១៣៖<br>ការលើកកម្ពស់ការងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | លោកបណ្ឌិត ម៉ៅ មីនា | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម<br>រុក្ខាប្រមាញ់ និងនេសាទ |
| | អនុកម្មវិធីទី-៥.១៤៖<br>ការពង្រឹងសេវាគាំទ្ររដ្ឋបាល | | ២៥ អង្គភាពថវិកា (មន្ទីរកសិកម្ម<br>រុក្ខាប្រមាញ់ និងនេសាទ) |

## IV. ការកំណត់សូចនាករ និងគោលដៅសូចនាករ

ដើម្បីតាមដានវឌ្ឍនភាពនិងសមិទ្ធផលនៃការអនុវត្តកម្មវិធី ឬ យុទ្ធសាស្ត្រអាទិភាពនីមួយៗ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់នូវសូចនាករ និងគោលដៅសូចនាករដូចខាងក្រោម :

**តារាង ២. ការកំណត់សូចនាករ និងគោលដៅសូចនាករនៃកម្មវិធី**

| គោលបំណងគោលនយោបាយ និងកម្មវិធី | សូចនាករលទ្ធផលក្នុងឆ្នាំ /គោលដៅ | | | | លទ្ធផលចុងក្រោយ | |
|---|---|---|---|---|---|---|
| | សូចនាករ | ២០១៨ (អនុវត្ត) | ២០១៩ (បច្ចុប្បន្ន) | ២០២០ (គ្រោង) | សូចនាករ | គោលដៅ |
| កម្មវិធីទី-១៖ ការបង្កើនផលិតភាព ពិពិធកម្ម ដំណាំកសិកម្ម និងកសិ-ធុរកិច្ច | ១) ផលិតផលកសិកម្មសរុប (លានតោន) | ២៨,៤៧ | ២៩,៩៣ | ៣១,៤៨ | កំណើនផលិតកម្មដំណាំគ្រប់ប្រភេទ (%) | ៥% |
| | ២) អនុបាត (%) នៃពិពិធកម្មដំណាំ | ៦២,៣២ | ៦៣,៤៤ | ៦៤,៥៥ | កំណើនពិពិធកម្មដំណាំក្នុងរង្វង់ (%) | ១% |
| | ៣) ផលិតផលដំណាំកសិកម្មនាំចេញ (លានតោន) | ៥,៤៩ | ៥,៨៧ | ៦,២៩ | កំណើនផលិតផលដំណាំកសិកម្មនាំចេញ (%) | ៧% |
| កម្មវិធីទី-២៖ ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ | ១) ផលិតផលសាច់សរុបកើន (ពាន់តោន) | ៣០៧ | ៣១៦ | ៣២៥ | កំណើនផលិតកម្មសាច់សត្វ (%) | ៣% |
| | ២)អត្រានៃការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មកើនឡើង (%) | ១៩,៩ | ២០,៣ | ២០,៧ | អត្រានៃការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មកើនឡើង (%) | ០,៣%/ឆ្នាំ |
| | ៣) អត្រានៃការចិញ្ចឹមគោកាត់កើនឡើង | ១៨ | ២០ | ២៣ | អត្រានៃការចិញ្ចឹមគោកាត់ កើនឡើង | ៣%/ឆ្នាំ |

| | | | | | | |
|---|---|---|---|---|---|---|
| **កម្មវិធីទី-៣៖**<br>**ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម** | ១. ផលនេសាទចាប់ពីធម្មជាតិ (ពាន់តោន) | ៦០០ | ៦០០ | ៦០០ | រក្សាបរិមាណផលិតកម្មនេសាទថេរ | ៦០០ ពាន់តោន/ឆ្នាំ |
| | ២. អត្រាផលវារីវប្បកម្មធៀបនឹងផលនេសាទសរុប(%) | ២៥ | ៣២ | ៣៦ | កំណើនផលិតកម្មវារីវប្បកម្ម (%) | ២០% |
| **កម្មវិធីទី-៤៖**<br>**ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ** | ១. ផ្ទៃដីដាំឈើ រដ្ឋនិងឯកជន (ហិកតា) | ២៥.០០០ | ២០.០០០ | ២០.០០០ | ផ្ទៃដីដាំឈើ រដ្ឋនិងឯកជន (ហិកតា) | ២៥.០០០ ហត/ឆ្នាំ |
| | ២.អត្រាចំណូលសហគមន៍ព្រៃឈើត្រូវបានកើនឡើង | ២០ | ២០ | ២០ | អត្រាចំណូលសហគមន៍ព្រៃឈើត្រូវបានកើនឡើង | ២០%/ឆ្នាំ |
| **កម្មវិធីទី-៥៖**<br>**ការបង្កើនប្រសិទ្ធភាព សេវាគាំទ្រ និងការអភិវឌ្ឍធនធានមនុស្ស** | ១. អនុបាត (%) នៃការអនុវត្តសកម្មភាពសម្រាប់ថវិកាកម្មវិធី | ៩៣ | ៩៤ | ៩៥ | អនុបាតនៃការអនុវត្តសកម្មភាព សម្រាប់ថវិកាកម្មវិធី (%) | ៩៦% |
| | ២. ភាគរយនៃនិស្សិតទទួលបានការងារធ្វើឬបង្កើតមុខរបរថ្មីក្រោយបញ្ចប់ការសិក្សា (%) | ៩៣ | ៩៤ | ៩៥ | ភាគរយនៃនិស្សិតទទួលបានការងារធ្វើឬបង្កើតមុខរបរថ្មីក្រោយ បញ្ចប់ការសិក្សា (%) | ៩៥%/ឆ្នាំ |
| | ៣. អនុបាតប្រសិទ្ធភាពនៃការអនុវត្តអនុសាសន៍កែលម្អរបស់ សវនដ្ឋាន (%) | | ៧២ | ៧៥ | កំណើនចំនួនមន្ត្រីទទួលបានការបណ្តុះបណ្តាល | ៣១០នាក់/ឆ្នាំ |

## តារាង ២. ការកំណត់សូចនាករ/គោលដៅសូចនាករនៃអនុកម្មវិធី

| គោលបំណងគោលនយោបាយ កម្មវិធី/យុទ្ធសាស្ត្រអាទិភាព | សូចនាករលទ្ធផលក្នុងឆ្នាំ /គោលដៅ | | | | លទ្ធផលចុងក្រោយ | |
|---|---|---|---|---|---|---|
| | សូចនាករ | ២០១៨ (អនុវត្ត) | ២០១៩ (បច្ចុប្បន្ន) | ២០២០ (គ្រោង) | សូចនាករ | គោលដៅ |
| **កម្មវិធីទី-១៖** | | | | | | |
| <u>អនុកម្មវិធីទី-១.១ ៖</u><br>ការអភិវឌ្ឍដំណាំស្រូវ | ១. បរិមាណផលស្រូវផលិតបាន (លានតោន) | ១០,៧៣ | ១០,៨៧ | ១១,១៨ | | |
| | ២. ការជំរុញអភិវឌ្ឍន៍ដំណាំស្រូវ (ពាន់តោន) | ៦២៦ | ៦៦០ | ៧១០ | | |
| <u>អនុកម្មវិធីទី-១.២ ៖</u><br>ការជំរុញការអភិវឌ្ឍដំណាំសាកវប្បកម្ម | ១. បរិមាណផលដំណាំសាកវប្បកម្ម (លានតោន) | ០,៧១ | ០,៧៤ | ០,៧៩ | | |
| | ២. បរិមាណដំណាំសាកវប្បកម្មនាំចេញសំខាន់ៗ (ពាន់តោន) | ១០ | ១២ | ១៣ | | |
| <u>អនុកម្មវិធីទី-១.៣ ៖</u><br>ការជំរុញការអភិវឌ្ឍដំណាំឧស្សាហកម្ម | ១. ប្របរិមាណផលដំណាំឧស្សាហកម្ម (លានតោន) | ១៥,៩៣ | ១៦,៥០ | ១៨,៤៣ | | |
| | ២. បរិមាណផលដំណាំឧស្សាហកម្មនាំចេញសំខាន់ៗ (លានតោន) | | | ៤,៣៤ | | |
| <u>អនុកម្មវិធីទី-១.៤ ៖</u><br>ការពង្រឹងសមត្ថភាពអង្គភាព និងការផ្តល់សេវាគាំទ្រ | ១.អនុបាត(%)នៃការអនុវត្តថវិកាប្រកបដោយប្រសិទ្ធភាព | ៩៥,៨៧ | ៩៥ | ៩៥ | | |
| | ២. ផលិតផលកសិកម្មនាំចេញដែលមានវិញ្ញាបនបត្រភូតគាមអនាម័យ | ៤,២៣ | ៥,៨៧ | ៦,២៩ | | |

| | | | | | | |
|---|---|---|---|---|---|---|
| **អនុកម្មវិធីទី-១.៥ ៖**<br>ការជំរុញការអភិវឌ្ឍកៅស៊ូធម្មជាតិ | ១. ផលិតផលកៅស៊ូកើនឡើង ១០% (ពាន់តោន) | ២២០,១ | ២៩២ | ៣៥៣ | | |
| | ២.ផ្ទៃដីចៀរ(ពាន់ហិកតា) | ២០១,៩ | ២៥៤ | ៣០៦ | | |
| **អនុកម្មវិធីទី-១.៦ ៖**<br>ការលើកកម្ពស់គុណភាពការងារពិសោធន៍ និងស្រាវជ្រាវកៅស៊ូ | ១.កំណើនក្លូនកៅស៊ូនៅវិទ្យាស្ថាន | ២ | ២ | ២ | | |
| | ២.អត្រា (%) នៃការចុះត្រួតពិនិត្យ និងវាយតម្លៃរោងចក្រកៅស៊ូ | ២ | ២ | ២ | | |
| **អនុកម្មវិធីទី-១.៧៖**<br>ការលើកកម្ពស់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម | ១.កំណើនបរិមាណផលិតផល កសិកម្មត្រូវបានធ្វើកិច្ចសន្យា(%) | ១០ | ១០ | ១០ | | |
| | ២. កំណើនការធ្វើអាជីវកម្មកែច្នៃផលិតផលកសិកម្ម (%) | ៥ | ៥ | ៥ | | |
| **អនុកម្មវិធីទី-១.៨ ៖**<br>ការស្រាវជ្រាវដើម្បីអភិវឌ្ឍកសិកម្មប្រកបដោយចីរភាព | ១. ចំនួនពូជដំណាំថ្មីញេញដោយកាឌី(ពូជ) | ២ | ៣ | ២ | | |
| | ២. កំណើនបរិមាណផលិតផល ដោយការប្រើប្រាស់បច្ចេកទេស ដែលបញ្ចេញ(%) | ២ | ៥ | ៥ | | |
| | ៣. កំណើនប្រសិទ្ធភាពការងារស្រាវជ្រាវរបស់កាឌី (%) | ៨ | ៥ | ៨ | | |
| **កម្មវិធីទី-២៖** | **សូចនាករ** | **២០១៨ (អនុវត្ត)** | **២០១៩ (បច្ចុប្បន្ន)** | **២០២០ (គ្រោង)** | | |
| **អនុកម្មវិធីទី-២.១ ៖**<br>ការជំរុញផលិតកម្មសត្វ | ១. ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មកើនឡើង (លានក្បាល) | ១០,០៤ | ១១,០០ | ១២,១០ | | |
| | ២. គោកូនកាត់មានផលិតភាពខ្ពស់កើនឡើង (ពាន់ក្បាល) | ៥២៧ | ៥៩១ | ៦៥០ | | |

| | | | | | | |
|---|---|---|---|---|---|---|
| **អនុកម្មវិធីទី-២.២ ៖** ការលើកកម្ពស់សុខភាពសត្វ | ១. អត្រាគោ-ក្របីបានចាក់វ៉ាក់សាំង (%) | ៦៣ | ៧៥ | ៧៧ | | |
| | ២. សត្តឃាតដ្ឋានបានអនុវត្តអនាម័យ និង សុវត្ថិភាពសាច់តាមបច្ចេកទេស (%) | ២៥ | ៣៥ | ៤៥ | | |
| **អនុកម្មវិធីទី-២.៣ ៖** ការពង្រឹងសមត្ថភាព និងសេវាគាំទ្រអង្គភាព | ១.ប្រសិទ្ធភាពនៃការអនុវត្តថវិកា | ៩២,៣ | ៩៣ | ៩៤ | | |
| | ២.ចំនួនកសិករ និងពាក់ព័ន្ធទទួល បាន ការផ្សព្វផ្សាយ បណ្តុះបណ្តាល បច្ចេកទេស ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ (នាក់) | ១៥៤៣ | ២០០០ | ២១០០ | | |
| **កម្មវិធីទី-៣៖** | | **២០១៨ (អនុវត្ត)** | **២០១៩ (បច្ចុប្បន្ន)** | **២០២០ (គ្រោង)** | | |
| **អនុកម្មវិធីទី៣.១៖** ការគ្រប់គ្រង និងការអភិរក្សធនធានជលផល | ១.ផលនេសាទចាប់ពីទឹកសាប (ពាន់តោន) | ៥៣៥ | ៥០០ | ៥០០ | | |
| | ២.ផលនេសាទចាប់ពីសមុទ្រ (ពាន់តោន) | ១២១ | ១០០ | ១០០ | | |
| **អនុកម្មវិធីទី៣.២៖** ការអភិវឌ្ឍវារីវប្បកម្ម និងខ្សែច្រវាក់តម្លៃជលផល | ១. ផលិតផលវារីវប្បកម្មទឹកសាប (ពាន់តោន) | ២៣៧ | ២៨៥ | ៣៤១ | | |
| | ២.ផលិតផលវារីវប្បកម្មសមុទ្រ (ពាន់តោន) | ១៧ | ២០ | ២៤ | | |
| | ៣.ចំនួនកន្លែងកែច្នៃជលផល បានអនុវត្តលក្ខខណ្ឌអនាម័យល្អ | ៥ | ៨ | ១០ | | |
| **អនុកម្មវិធីទី៣.៣៖** ការពង្រឹងសមត្ថភាព និងសេវាគាំទ្រអង្គភាព | ១.ការអនុវត្តផែនការសកម្មភាព ក្នុងអនុវិស័យជលផលប្រចាំឆ្នាំ(%) | ៩៣ | ៩៤ | ៩៨ | | |
| | ២. អត្រាអ្នកពាក់ព័ន្ធទទួល ចំណេះដឹង ច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ(%) | ៥ | ៥ | ៥ | | |

| កម្មវិធីទី-៤៖ | | ២០១៨ (អនុវត្ត) | ២០១៩ (បច្ចុប្បន្ន) | ២០២០ (គ្រោង) | | |
|---|---|---|---|---|---|---|
| **អនុកម្មវិធីទី៤.១៖**<br>**ការគ្រប់គ្រងព្រៃឈើ** | ១.អត្រាចំណូលសហគមន៍ព្រៃឈើត្រូវបានកើនឡើង(%) | ២០ | ២០ | ២០ | | |
| | ២.ចំនួនរោងសន្និធិ និងរោងសិប្បកម្មត្រូវបានពង្រឹង និងគ្រប់គ្រង ( ទីតាំង ) | ២០០ | ១០០ | ១០០ | | |
| | ៣.ចំនួនសំណុំរឿងបទល្មើសព្រៃឈើត្រូវបានពិនិត្យ ផ្ទៀតផ្ទាត់ និងធ្វើបច្ចុប្បន្នភាព (ករណី) | ១៥០ | ៩០០ | ៩០០ | | |
| **អនុកម្មវិធីទី៤.២៖**<br>**ការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍព្រៃឈើនិងសត្វព្រៃ** | ១.ចំនួនផ្ទៃដីដាំឈើ រដ្ឋនិងឯកជន (ហិកតា) | ២៥.០០០ | ២០.០០០ | ២០.០០០ | | |
| | ២.ចំនួនទីតាំងថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារនិងកសិដ្ឋានចិញ្ចឹមសត្វត្រូវបានចុះបញ្ជិកា ( ទីតាំង ) | ២៥ | ២៥ | ៣០ | | |
| | ៣.ផ្ទៃដីឡូត៍ស្រាវជ្រាវត្រូវបានបង្កើត (ហិកតា) | ២០ | ៣៥ | ៤២ | | |
| **អនុកម្មវិធីទី៤.៣៖**<br>**ការពង្រឹងការគ្រប់គ្រង និងសេវាគាំទ្រ** | ១.លទ្ធផលនៃការអនុវត្តផែនការ ថវិកា (%) | ៩០ | ៩០ | ៩២ | | |
| | ២. លទ្ធផលនៃការអនុវត្តផែនការសកម្មភាព (%) | ៩០ | ៩០ | ៩២ | | |

| កម្មវិធីទី-៥៖ | | ២០១៨ (អនុវត្ត) | ២០១៩ (បច្ចុប្បន្ន) | ២០២០ (គ្រោង) | | |
|---|---|---|---|---|---|---|
| **<u>អនុកម្មវិធីទី៥.១៖</u>** **ការលើកកម្ពស់ការកសាងនិងការអនុវត្តផែនការគោលនយោបាយ និងវិនិយោគកសិកម្ម (នផក)** | ១. អនុបាត (%) នៃការអនុវត្ត សកម្មភាពសម្រាប់ថវិកាកម្មវិធី | ៩១ | ៩៣ | ៩៤ | | |
| | ២. ចំនួនសំណាកនៃការអង្កេត ស្ទង់ទិន្នផលស្រូវ (សំណាក) | ១២.០០០ | ១២.៥០០ | ១៣.០០០ | | |
| | ៣. ចំនួន SMS ត្រូវបានប្រើប្រាស់សម្រាប់ព័ត៌មានទីផ្សារកសិកម្ម (SMS/ឆ្នាំ) | ២០.០០០ | ២១.០០០ | ២២.០០០ | | |
| **<u>អនុកម្មវិធីទី៥.២៖</u>** **ការបង្កើនប្រសិទ្ធភាពការរៀបចំគ្រប់គ្រង និងការអនុវត្តថវិកា (នគហ)** | ១. អត្រា (%) នៃអ្នកប្រើប្រាស់ប្រព័ន្ធគណនេយ្យ ហិរញ្ញវត្ថុក្នុងកុំព្យូទ័រ | ៥០ | ៧០ | ៧២ | | |
| | ២. អត្រា (%) នៃការអនុវត្តថវិកា | ៩៤ | ៩៦ | ៩៦ | | |
| **<u>អនុកម្មវិធីទី៥.៣៖</u>** **ការគ្រប់គ្រងស្ថាប័ន និងអភិវឌ្ឍន៍ធនធានមនុស្ស (នបុ.អភធ)** | ១-ចំនួនអង្គភាពត្រូវបានចុះសិក្សា ត្រួតពិនិត្យ និងវាយតម្លៃ និងកែលម្អលើការគ្រប់គ្រង មន្ត្រីរាជការ | | ១៣ | ៤៥ | | |
| | ២-ចំនួនវគ្គការបណ្តុះបណ្តាល ផ្សព្វផ្សាយ និងពង្រឹងសមត្ថភាព មន្ត្រីកសិកម្ម | | ១៥ | ១៥ | | |
| | ៣. ចំនួនមន្ត្រីទទួលបាន ការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស | ៣៩០០ | ៤១៤៣ | ៤៣៤០ | | |
| **<u>អនុកម្មវិធីទី៥.៤៖</u>** **ការបង្កើនប្រសិទ្ធភាពការងារសវនកម្មផ្ទៃក្នុង (នសវក)** | ១. អនុបាត (%) ប្រសិទ្ធភាព នៃការអនុវត្តអនុសាសន៍កែលម្អរបស់សវនដ្ឋាន | ៤៨ | ៥០ | ៥២ | | |

| | | | | | | |
|---|---|---|---|---|---|---|
| **អនុកម្មវិធីទី៥.៥៖**<br>ការលើកកម្ពស់សមត្ថភាព និងប្រសិទ្ធភាពការងារសហប្រតិបត្តិការអន្តរជាតិ (នសហ) | ១. កិច្ចហសការណ៍ជាមួយ ដៃគូអភិវឌ្ឍន៍តាមរយៈការអនុវត្តគម្រោងអភិ. (គម្រោង) | ២០ | ១៥ | ២៥ | | |
| | ២. ចំនួនវគ្គបណ្តុះបណ្តាល ប្រជុំ សិក្ខាសាលា និងសន្និសិទ្ធ | ៨០ | ៦៩ | ១០៩ | | |
| | ៣.ចំនួនចុះតាមដាននិងវាយតម្លៃការអនុវត្តគម្រោង ឥណទាននិង NGO (លើក) | ១៦ | ៨ | ២១ | | |
| **អនុកម្មវិធីទី៥.៦៖**<br>ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ពាក់ព័ន្ធការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម (ននក) | ១. ចំនួនដេប៉ូធ្វើអាជីកម្ម សម្ភារកសិកម្មក្នុងខេត្តគោលដៅចំនួន១៥ ត្រូវបានត្រួតពិនិត្យនិងណែនាំ (ដេប៉ូ) | ៤១៥ | ៤២០ | ៥៣០ | | |
| | ២. ចំនួនមន្ត្រី អាជ្ញាធរដែនដី និងអាជីវករសម្ភារកសិកម្ម ត្រូវបានបណ្តុះបណ្តាល (នាក់) | ១០៥០ | ១១៥០ | ១១៧៥ | | |
| **អនុកម្មវិធីទី៥.៧៖**<br>ការពង្រឹងការងាររដ្ឋបាល និងការបញ្ជ្រាបយេនឌ័រ (នាយកដ្ឋានកិច្ចការរដ្ឋបាល) | ១. ចំនួនមន្ត្រីរាជការទទួលបាន ការបណ្តុះបណ្តាលក្នុងការងារ កិច្ចការរដ្ឋបាលទូទៅ (នាក់) | ៣០ | ៣០ | ៣០ | | |
| | ២. ចំនួនមន្ត្រីរាជការ កសិករទទួលបានការបណ្តុះបណ្តាល ស្តីពីការបញ្ជ្រាប យេនឌ័រក្នុងផលិតកម្មកសិកម្មតាមខេត្ត (នាក់) | ៣០០ | ៣០០ | ៣០០ | | |
| **អនុកម្មវិធីទី៥.៨៖**<br>ការបង្កើនប្រសិទ្ធភាពការងារអធិការកិច្ច (អគ្គាធិការដ្ឋាន) | ១. ចំនួនអង្គភាពត្រូវបានចុះធ្វើអធិការកិច្ច(អង្គភាព) | ១៩ | ២៨ | ៣០ | | |
| | ២. ចំនួនសិក្ខាកាមត្រូវ បានបណ្តុះបណ្តាល (នាក់) | ១៦៩ | ១៤០ | ១៤០ | | |

| | | | | | | |
|---|---|---|---|---|---|---|
| **<u>អនុកម្មវិធីទី៥.៩៖</u>** ការគ្រប់គ្រងឯកសារនិងប្រព័ន្ធព័ត៌មានកសិកម្ម (AIDOC) | ១. គេហទំព័រ (Web) និងMobile App របស់ក្រសួងត្រូវបានថែទាំ | ១៧ | ១៧ | ១៧ | | |
| | ២. គេហទំព័រ និងរបស់មន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៨ | ១០ | ២៥ | | |
| | ៣. ព័ន្ធផ្សព្វផ្សាយព័ត៌មានវិស័យ កសិកម្ម ត្រូវបានពង្រឹង (Social Media, E-Library, Video Clip, Web GIS) | ៤ | ៤ | ៥ | | |
| **<u>អនុកម្មវិធីទី៥.១០៖</u>** ការពង្រឹងគុណភាពអប់រំ និងបណ្តុះបណ្តាលធនធានមនុស្សលើបច្ចេកទេសកសិកម្មនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម | ១. ចំនួននិស្សិតដែលបញ្ចប់ ការសិក្សាគ្រប់កម្រិត (នាក់) | ៦៧៧ | ៧៥០ | ៨០០ | | |
| | ២. ចំនួនអត្ថបទសិក្សា វិទ្យាសាស្ត្រ ត្រូវបានបោះពុម្ព | ១៧ | ១៧ | ២០ | | |
| **<u>អនុកម្មវិធីទី៥.១១៖</u>** ការលើកកម្ពស់គុណភាពអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្មនៅសាលាជាតិកសិកម្មព្រែកលៀប | ១. ចំនួននិស្សិតបណ្តុះបណ្តាល | ១០២០ | ៩៨៨ | ៩៨៨ | | |
| | ២. ចំនួនមន្ត្រីរាជការបាន បណ្តុះបណ្តាលក្នុងឆ្នាំនីមួយៗ | ២០ | ២៥ | ៣០ | | |
| **<u>អនុកម្មវិធីទី៥.១២៖</u>** ការពង្រឹងគុណភាពប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលធនធានមនុស្សវិស័យកសិកម្ម របស់សាលាជាតិកសិកម្មកំពង់ចាម | ១. ចំនួននិស្សិតបានបណ្តុះបណ្តាល (នាក់) | ៩៥០ | ៩៥០ | ៩៥០ | | |
| | ២. ចំនួនគម្រោងស្រាវជ្រាវ (គម្រោង) | ១៥ | ១៥ | ១៥ | | |
| | ៣. ចំនួនសិក្ខាសាលានិងបណ្តុះបណ្តាល (វគ្គ) | ៣ | ៣ | ៣ | | |
| **<u>អនុកម្មវិធីទី៥.១៣៖</u>** ការលើកកម្ពស់ការងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១. មន្ត្រីផ្តល់សេវាផ្សព្វផ្សាយត្រូវបានពង្រឹងសមត្ថភាព (ភាគរយ) | ៤០ | ៥០ | ៦០ | | |
| | ២. អ្នកទទួលបានសេវាផ្សព្វផ្សាយ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ភាគរយ) | ៣៦ | ៣៧ | ៣៨ | | |

## V. ការកំណត់ធនធាន

### ក. ការកំណត់តម្រូវការចំណាយ

តារាង ៤.១÷ ការកំណត់តម្រូវការចំណាយសម្រាប់កម្មវិធី២០២០-២០២២ (រដ្ឋបាលកណ្ដាល)

ឯកត្តា លានរៀល

| តម្រូវការធនធានតាមប្រភេទចំណាយ | ច្បាប់ឆ្នាំ២០១៩ | | | គ្រោងតម្រូវការធនធានឆ្នាំ២០២០ | | | គ្រោងតម្រូវការធនធានឆ្នាំ២០២១ | | | គ្រោងតម្រូវការធនធានឆ្នាំ២០២២ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ |
| **សរុបរួម** | 221,071.60 | 38,024.70 | 4,417.50 | 357,433.30 | 27,194.40 | 4,311.90 | 266,645.19 | 28,698.80 | 4,507.50 | 272,092.41 | 23,050.80 | 4,077.61 |
| **-សរុបចំណាយចរន្ត** | 221,071.60 | - | 4,417.50 | 166,916.30 | - | 4,311.90 | 172,634.19 | - | 4,507.50 | 178,561.41 | - | 4,077.61 |
| បន្ទុកបុគ្គលិក | 65,746.60 | - | 3,906.00 | 76,872.30 | - | 3,456.70 | 78,443.50 | - | 3,623.49 | 80,673.85 | - | 3,798.61 |
| ក្រៅពីបន្ទុកបុគ្គលិក | 155,325.00 | - | 511.50 | 90,044.00 | - | 855.20 | 94,190.69 | - | 884.01 | 97,887.56 | - | 279.00 |
| **-សរុបចំណាយមូលធន** | - | 38,024.70 | - | 190,517.00 | 27,194.40 | - | 94,011.00 | 28,698.80 | - | 93,531.00 | 23,050.80 | - |
| + គម្រោងវិនិយោគ | - | 3,402.30 | - | 190,517.00 | 11,224.80 | - | 94,011.00 | 10,804.80 | - | 93,531.00 | 10,804.80 | - |
| *គម្រោងមានហិរញ្ញប្បទាន* | - | 3,402.30 | - | - | 11,224.80 | - | - | 10,804.80 | - | - | 10,804.80 | - |
| *គម្រោងមិនទាន់មានហិរញ្ញប្បទាន* | - | - | - | 190,517.00 | - | - | 94,011.00 | - | - | 93,531.00 | - | - |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| +ជំនួយបច្ចេកទេស | - | 34,622.40 | - | - | 15,969.60 | - | - | 17,894.00 | - | - | 12,246.00 | - |
| *គម្រោងមានហិរញ្ញប្បទាន* | - | 28,122.40 | - | - | 10,117.60 | - | - | 12,246.00 | - | - | 12,246.00 | - |
| *គម្រោងមិនទាន់មានហិរញ្ញប្បទាន* | - | 6,500.00 | - | - | 5,852.00 | - | - | 5,648.00 | - | - | - | - |
| កម្មវិធីទី១ ៖ ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច | | | | | | | | | | | | |
| សរុបកម្មវិធីទី១ | 40,837.10 | - | 170.00 | 134,933.42 | - | 170.00 | 135,585.42 | - | 170.00 | 136,914.28 | - | 170.00 |
| សរុបចំណាយចរន្ត | 40,837.10 | - | 170.00 | 48,416.42 | - | 170.00 | 49,574.42 | - | 170.00 | 51,383.28 | - | 170.00 |
| បន្ទុកបុគ្គលិក | 16,969.20 | - | - | 26,041.80 | - | - | 26,372.60 | - | - | 27,224.15 | - | - |
| ក្រៅពីបន្ទុកបុគ្គលិក | 23,867.90 | - | 170.00 | 22,374.62 | - | 170.00 | 23,201.82 | - | 170.00 | 24,159.13 | - | 170.00 |
| អនុកម្មវិធីទី-១.១ ៖ ការអភិវឌ្ឍដំណាំស្រូវ (GDA) | - | - | - | 2,687.00 | - | - | 2,773.00 | - | - | 2,879.00 | - | - |
| អនុកម្មវិធីទី-១.២ ៖ ការជំរុញការអភិវឌ្ឍដំណាំសាកវប្បកម្ម (GDA) | - | - | - | 1,580.00 | - | - | 1,632.00 | - | - | 1,687.00 | - | - |
| អនុកម្មវិធីទី-១.៣ ៖ ការជំរុញការអភិវឌ្ឍដំណាំឧស្សាហកម្ម (GDA) | - | - | - | 1,259.00 | - | - | 1,301.00 | - | - | 1,344.00 | - | - |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| អនុកម្មវិធីទី-១.៤ ៖ ការពង្រឹងសមត្ថភាពអង្គភាព និងការផ្ដល់សេវាគាំទ្រ (GDA) | - | - | - | 6,695.20 | - | - | 6,857.00 | - | - | 7,127.00 | - | - |
| អនុកម្មវិធីទី-១.៥ ៖ ការជំរុញការអភិវឌ្ឍកៅស៊ូធម្មជាតិ (អគ្គ.កៅស៊ូ) | 2,114.20 | - | - | 2,113.42 | - | - | 2,176.82 | - | - | 2,242.13 | - | - |
| អនុកម្មវិធីទី-១.៦៖ ការលើកកម្ពស់គុណភាពការងារពិសោធន៍ និងស្រាវជ្រាវកៅស៊ូ IRCC | 1,870.00 | - | - | 1,870.00 | - | - | 1,908.00 | - | - | 1,909.00 | - | - |
| អនុកម្មវិធីទី-១.៧ ៖ ការលើកកម្ពស់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម DAI | 1,957.00 | - | - | 2,050.00 | - | - | 2,310.00 | - | - | 2,600.00 | - | - |
| អនុកម្មវិធីទី-១.៨: ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កសិកម្មប្រកបដោយចីរភាព(CARDI) | 4,330.00 | - | 170.00 | 4,120.00 | - | 170.00 | 4,244.00 | - | 170.00 | 4,371.00 | - | 170.00 |
| -សរុបចំណាយមូលធន | - | - | - | 86,517.00 | - | - | 86,011.00 | - | - | 85,531.00 | - | - |
| +គម្រោងវិនិយោគ | - | - | - | 86,517.00 | - | - | 86,011.00 | - | - | 85,531.00 | - | - |
| គម្រោងមានហិរញ្ញប្បទាន | - | - | - | - | - | - | - | - | - | - | - | - |
| គម្រោងមិនទាន់មានហិរញ្ញប្បទាន | - | - | - | 86,517.00 | - | - | 86,011.00 | - | - | 85,531.00 | - | - |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| +ជំនួយបច្ចេកទេស | - | - | - | - | - | - | - | - | - | - | - | - |
| គម្រោងមានហិរញ្ញប្បទាន | - | - | - | - | - | - | - | - | - | - | - | - |
| គម្រោងមិនទាន់មានហិរញ្ញប្បទាន | - | - | - | - | - | - | - | - | - | - | - | - |
| កម្មវិធីទី២ ៖ រលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ | | | | | | | | | | | | |
| សរុបកម្មវិធីទី២ | 19,896.90 | - | - | 123,896.90 | - | - | 27,896.90 | - | - | 27,896.90 | - | - |
| សរុបចំណាយចរន្ត | 19,896.90 | - | - | 19,896.90 | - | - | 19,896.90 | - | - | 19,896.90 | - | - |
